**Convention on the Rights of the Child – Khmer version (Cambodia)**



# អនុសញ្ញាស្តីពី សិទ្ធិកុមារ

*អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នាថ្ងៃ២០ វិច្ឆិកា ១៩៨៩*

## សេចក្តីផ្តើម

**រដ្ឋជាភាគីទាំងឡាយនៃអនុសញ្ញានេះ...**

ដោយសង្កេតឃើញថា អនុលោមតាមគោលការណ៍នានាដែលបានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ការទទួលស្គាល់នូវភាពថ្លៃថ្នូរដែលមិនអាចផ្តាច់ចេញបាន ហើយនិងសិទ្ធិស្មើភាព និង មិនអាចប៉ះពាល់បាននៃរាល់សមាជិកនៃគ្រួសារមនុស្សគឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និង សន្តិភាព នៅក្នុងពិភពលោក ។

ដោយចងចាំនៅក្នុងចិត្តថា ប្រជាជនទាំងឡាយនៃអង្គការសហប្រជាជាតិបានអះអាងសាជាថ្មីនៅក្នុងធម្មនុញ្ញនេះ នូវជំនឿជាក់ច្បាស់របស់ខ្លួនក្នុងសិទ្ធិជាគ្រឹះរបស់មនុស្ស ហើយនិងភាពថ្លៃថ្នូរ និងតម្លៃរបស់បុគ្គលមនុស្ស ហើយបានប្តេជ្ញាជំរុញឱ្យរីឡូនសង្គម និងលក្ខខ័ណ្ឌរស់នៅឱ្យកាន់តែប្រសើរឡើងក្នុងសេរីភាពមួយកាន់តែទូលំទូលាយជាង ។

ដោយទទួលស្គាល់ថា អង្គការសហប្រជាជាតិ នៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ហើយនិងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស បានប្រកាសនិងឯកភាពថា បុគ្គលគ្រប់រូបសុទ្ធតែត្រូវទទួលបាននូវសិទ្ធិ និង សេរីភាពដែលមានចែងនៅក្នុងឯកសារទាំងនោះ ដោយគ្មានការបែងចែកអ្វីទាំងអស់ ដូចជា ពូជសាសន៍ ភេទ សាសនា នយោបាយ ឬមតិយោបល់ផ្សេងៗ សញ្ជាតិ ឬប្រភពសង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពផ្សេងៗទៀតជាដើម ។

ដោយរំលឹកឡើងវិញ នៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស អង្គការសហប្រជាជាតិបានប្រកាសថា កុមារត្រូវទទួលបាននូវកិច្ចថែទាំ និងការជួយឧបត្ថម្ភជាពិសេស ។

ដោយមានជំនឿថា គ្រួសារ ក្នុងនាទីជាអង្គភាពគ្រឹះនៃសង្គម ហើយនិងជាបរិស្ថានធម្មជាតិសំរាប់ការរីកចំរើនលូតលាស់ និង ជាផាសុកភាពរបស់សមាជិកខ្លួនទាំងមូល ហើយដែលមានកុមារជាពិសេសនោះ ត្រូវតែឱ្យមានកិច្ចគាំពារ និងជំនួយឧបត្ថម្ភចាំបាច់ ដើម្បីខ្លួនអាចបំពេញភារកិច្ចទទួលខុសត្រូវរបស់ខ្លួនបានពេញលេញក្នុងសមាគមន៍បាន ។ ខ្លួនដោយពេញលេញ និងសុខដុមបានកុមារត្រូវធំលូតលាស់ឡើងនៅក្នុងមជ្ឈដ្ឋានគ្រួសារ នៅក្នុងបរិយាកាសប្រកបដោយសុភមង្គល សេចក្តីស្រឡាញ់ និង ការយោគយល់មួយ ។

ដោយសង្កេតឃើញថា កុមារត្រូវតែមានការរៀបចំខ្លួនឱ្យបានពេញលេញដើម្បីរស់ក្នុងជីវិតជាបុគ្គលនៅក្នុងសង្គម ហើយនិងត្រូវមានការអប់រំក្នុងស្មារតីនៃឧត្តមគតិ ដែលបានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ជាពិសេស នៅក្នុងស្មារតីសន្តិភាព ភាពថ្លៃថ្នូរ ភាពអនុគ្រោះសេរីភាពស្មើភាព និង សាមគ្គីភាព ។

ដោយចងចាំនៅក្នុងចិត្តថា សេចក្តីត្រូវការនូវការពង្រីកកិច្ចថែទាំ ជាពិសេសចំពោះកុមារត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ក្រុងហ្សឺណែវស្តីពីសិទ្ធិកុមារ ឆ្នាំ១៩២៤ ហើយនិងក្នុងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារដែលត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិនាថ្ងៃទី២០ វិច្ឆិកា ១៩៥៩ ហើយដែលត្រូវទទួលស្គាល់នៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ជាពិសេសក្នុងមាត្រា២៣ និង ២៤) នៅក្នុងកតិការសញ្ញាអន្តរជាតិស្តីពិសិទ្ធិ សេដ្ឋកិច្ចសង្គមកិច្ច និង វប្បធម៌ (ជាពិសេសនៅក្នុងមាត្រា១០) ហើយនៅក្នុងលក្ខន្តិកៈ និង ឯកសារទាក់ទិននានារបស់អង្គការឯកទេស និង អង្គការអន្តរជាតិទាំងឡាយដែលទាក់ទិនទៅនឹងផាសុកភាពរបស់កុមារ ។

ដោយចងចាំនៅក្នុងចិត្តថា ដូចដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមាររួចមកហើយ "កុមារអាស្រ័យដោយភាពមិនទាន់ចាស់ទុំក្នុងផ្នែករាងកាយ និង សតិបញ្ញា រមែងត្រូវការការពារ និង ការថែទាំជាពិសេស រួមបញ្ចូលទាំងផ្នែកគាំពារផ្នែកផ្លូវច្បាប់ផង ទាំងនៅមុន និងក្រោយពេលប្រសូត្រចេញពី ផ្ទៃមាតា" ។

ដោយរំលឹកឡើងវិញថា បទបញ្ញត្តិនៃសេចក្តីថ្លែងការណ៍ ពីគោលការណ៍ច្បាប់ និងគោលការណ៍សង្គមទាំងឡាយ ដែលទាក់ទងដល់កិច្ចគាំពារ និង ផាសុកភាពរបស់កុមារ សំដៅពិសេសទៅលើការដាក់ឱ្យគេចិញ្ចឹម និង ការសុំកូនចិញ្ចឹមទាំងក្នុងកំរិតជាតិ និង អន្តរជាតិបញ្ញត្តិជាបទដ្ឋានអប្បបរមា

នៃអង្គការសហប្រជាជាតិស្ដីពីការងារយុត្តិធម៌ផ្នែកយុវជន (បញ្ញត្តិទីក្រុងប៉េកាំង) ហើយនិងសេចក្ដីថ្លែងការណ៍ស្ដីពីកិច្ចគាំពារនារី និងកុមារនៅក្នុងភាពមានអាសន្ន និងពេលមានជម្លោះដោយអាវុធ ។

ដោយទទួលស្គាល់ថា នៅក្នុងគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោកមានកុមារដែលកំពុងរស់នៅក្នុងស្ថានភាពដ៏លំបាកយ៉ាប់យ៉ឺនបំផុត ហើយកុមារទាំងនេះត្រូវការយកចិត្តទុកដាក់ជាពិសេស ។

ដោយបានគិតគូរយ៉ាងសមស្របដល់សារៈសំខាន់នៃតម្លៃប្រពៃណីនិងវប្បធម៌របស់ប្រជាជនទីមួយៗ នៅក្នុងកិច្ចគាំពារ ហើយនិងការចំរើនលូតលាស់ដោយសុខដុមរបស់កុមារ ។

ដោយទទួលស្គាល់ ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិដើម្បីលើកកំពស់ល័ក្ខខ័ណ្ឌរស់ នៅរបស់កុមារនៅក្នុងប្រទេសនីមួយៗជាពិសេសនៅក្នុងប្រទេសកំពុងលូតលាស់ ។

បានឯកភាពដូចខាងក្រោមនេះ :

## ភាគ ១

### មាត្រា ១

ក្នុងគោលដៅនៃអនុសញ្ញានេះ កុមារមានន័យថា មនុស្សគ្រប់រូបដែលមានអាយុតិចជាងដប់ប្រាំបីឆ្នាំ លើកលែងតែអាយុពេញវ័យត្រូវបានគេសន្មត់រហ័សជាងនេះ អាស្រ័យដោយអនុលោមតាមច្បាប់សំរាប់អនុវត្តចំពោះកុមារ ។

### មាត្រា ២

១. រដ្ឋជាភាគីត្រូវគោរព និង ធានានូវសិទ្ធិទាំងប៉ុន្មានដែលមានចែងនៅក្នុងអនុសញ្ញានេះ ចំពោះរាល់កុមារដែលស្ថិតក្នុងដែនអំណាចរបស់ខ្លួន ដោយគ្មានការរើសអើងអ្វីទាំងអស់ លើផ្នែកពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា សាសនា មតិនយោបាយ ឬ មតិផ្សេងៗ សញ្ជាតិ ប្រភពសាសន៍ ឬ ប្រភពសង្គម ទ្រព្យសម្បត្តិ អសមត្ថភាព ស្ថានភាពកំណើត ស្ថានភាពអ្វីផ្សេងទៀត របស់កុមារ ឬរបស់ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួនឡើយ ។

២. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងឡាយដើម្បីធានាឱ្យកុមារមានកិច្ចគាំពារតទល់នឹងរាល់ទំរង់នៃការរើសអើស ឬការផ្ដន្ទាទោសដែលឈរលើមូលដ្ឋាននៃលក្ខន្តិកៈបុគ្គលិក

សកម្មភាពការបញ្ចេញមតិ ឬ ជំនឿសាសនារបស់ឪពុកម្ដាយ អ្នកអាណាព្យាបាលស្របច្បាប់ ឬ សមាជិកនានានៃគ្រួសាររបស់កុមារនោះ ។

**មាត្រា ៣**

១. នៅក្នុងសកម្មភាពទាំងអស់ដែលមានទាក់ទិននឹងកុមារ ទោះជាសកម្មភាពនោះត្រូវបានធ្វើឡើងដោយស្ថាប័នសង្គមកិច្ចសាធារណៈ ឬ ឯកជនដោយតុលាការ អាជ្ញាធររដ្ឋបាល ឬ ដោយស្ថាប័ននីតិសាស្ត្រក្ដី ក៏ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ ត្រូវតែចាត់ទុកថាជាការចំបង ។

២. រដ្ឋជាភាគីសន្យាថានឹងធានាដល់កុមារនូវកិច្ចគាំពារ និង ការថែទាំងទាំងឡាយដែចាំបាច់ដល់ផាសុកភាពរបស់កុមារ ដោយគិតគូរដល់សិទ្ធិនិងករណីយកិច្ចឪពុកម្ដាយ អ្នកអាណាព្យាបាលស្របច្បាប់ ហើយនិងបុគ្គលឯទៀតដែលទទួលខុសត្រូវស្របច្បាប់លើកុមារ ហើយក្នុងទិសដៅនេះត្រូវប្រកាន់យកនូវរាល់វិធានការផ្នែកច្បាប់ និង ផ្នែករដ្ឋបាលទាំងឡាយដែលសមស្រប ។

៣. រដ្ឋជាភាគីធានាថា ស្ថាប័នកិច្ចទំនុកបំរុង ហើយនិងគ្រឿងឧបករណ៍ទាំងឡាយសំរាប់ថែរក្សា និង គាំពារកុមារត្រូវមានលក្ខណៈត្រឹមត្រូវស្របទៅតាមបទដ្ឋាន (ខ្នាត) ដែលអាជ្ញាធរមានសមត្ថកិច្ចតម្រូវឱ្យនៅក្នុងចំនួន និង សម្បទានៃបុគ្គលិករបស់ខ្លួន ព្រមទាំងនៅក្នុងការត្រួតពិនិត្យគ្រប់គ្រងដ៏មានសមត្ថកិច្ចផងដែរ ជាពិសេសនៅក្នុងវិស័យសន្តិសុខ និងសុខភាព ។

**មាត្រា ៤**

រដ្ឋជាភាគីនឹងប្រកាន់យកវិធានការសមប្រទាំងអស់ ទាំងផ្នែកច្បាប់ ផ្នែករដ្ឋបាល និង ផ្នែកផ្សេងៗទៀត ក្នុងការដាក់ឱ្យប្រើប្រាស់នូវសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ ចំពោះសិទ្ធិដែលទាក់ទងដល់ផ្នែកសេដ្ឋកិច្ច សង្គម និង វប្បធម៌វិញ រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការណ៍ទាំងអស់នេះនៅក្នុងក៏រិតអតិបរិមានៃប្រភពធនធានដែលខ្លួនមាន ហើយបើសិនជាចាំបាច់វិធានការនេះ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៥**

រដ្ឋជាភាគីត្រូវគោរពដល់ការទទួលខុសត្រូវគោរពសិទ្ធិ និង គោរពករណីយកិច្ចរបស់ឪពុកម្ដាយ ឬរបស់សមាជិកគ្រួសារដែលជាសាច់ញាតិឆ្ងាយៗ បើប្រសិនជាមាន ឬ ជាសមាជិកសហគមន៍ដែល

តាមទំនៀមទំលាប់ប្រចាំស្រុក គេចាត់ឱ្យមានអ្នកអាណាព្យាបាលស្របច្បាប់ ឬ អ្នកឯទៀតដែលទទួលខុសត្រូវតាមច្បាប់លើកុមារនៅក្នុងការផ្ដល់ដល់កុមារទៅតាមរបៀបមួយដែលស៊ីគ្នាទៅនឹងការរីកចំរើនលូតលាស់នៃសមត្ថភាពរបស់កុមារនោះ នូវការដឹកនាំ និង ដំបូន្មានសមស្របទៅនឹងការប្រើប្រាស់សិទ្ធិទាំងឡាយដែលត្រូវបានទទួលស្គាល់ដោយអនុសញ្ញានេះ ។

**មាត្រា ៦**

១.រដ្ឋជាភាគីទទួលស្គាល់ថា កុមារគ្រប់រូបសុទ្ធតែមានសិទ្ធិដើម្បីមានជីវិតដែលមិនអាចដកហូតបាន ។

២. រដ្ឋជាភាគីត្រូវធានាការរស់នៅ ព្រមទាំងការរីកចំរើនលូតលាស់របស់កុមារឱ្យបានដល់កំរិតខ្ពស់បំផុត ។

**មាត្រា ៧**

១. កុមារត្រូវបានចុះបញ្ជីអត្រានុកូលដ្ឋាន(បញ្ជីកំណើត)ភ្លាមក្រោយពេលប្រសូត្រមក ហើយមានសិទ្ធិក្នុងការមានឈ្មោះមួយ មានសិទ្ធិទទួលបានសញ្ជាតិមួយតាំងពីពេលកើតមកភ្លាម ហើយនិងមានសិទ្ធិស្គាល់ឪពុកម្ដាយខ្លួន ព្រមទាំងទទួលបានការថែទាំពីអ្នកទាំងនោះឱ្យបានពេញលេញបរិបូណ៌តាមតែអាចធ្វើទៅកើត ។

២. រដ្ឋជាភាគីត្រូវធានាដាក់សិទ្ធិទាំងនេះឱ្យអនុវត្តប្រើប្រាស់ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន ហើយនិងអនុលោមទៅតាមកាតព្វកិច្ចទាំងឡាយរបស់ខ្លួន ដែលមានចែងនៅក្នុងឯកសារអន្តរជាតិស្ដីអំពី ប្រការនេះ ពិសេស នៅក្នុងករណីដែលកុមារនឹងក្លាយទៅជាគ្មានសញ្ជាតិប្រសិនណាបើគ្មានឯកសារទាំងនោះ ។

**មាត្រា ៨**

១. រដ្ឋជាភាគីសន្យាថា គោរពដល់សិទ្ធិរបស់កុមារក្នុងការរក្សាទុកនូវអត្តសញ្ញាណរបស់ខ្លួនដោយរាប់បញ្ចូលទាំងសញ្ជាតិ ឈ្មោះ ព្រមទាំងទំនាក់ទំនងគ្រួសារ ដូចដែលបានទទួលស្គាល់តាមផ្លូវច្បាប់ ដោយគ្មានការលូកជ្រៀតជ្រែកចូលដោយខុសច្បាប់ឡើយ ។

២. ក្នុងករណីណាដែលកុមារទទួលការបាត់បង់ដោយខុសច្បាប់នូវធាតុនៃអត្តសញ្ញាណរបស់ខ្លួន ទោះមួយភាគ ឬក៏ទាំងស្រុងក្តី រដ្ឋជាភាគីត្រូវផ្តល់កិច្ចថែទាំ និង ជំនួយឧបត្ថម្ភឱ្យបានសមស្រប ដើម្បីធ្វើឱ្យមានឡើងវិញយ៉ាងឆាប់រហ័យនូវអត្តសញ្ញាណនេះ ។

**មាត្រា ៩**

១. រដ្ឋជាភាគីធានាថា កុមារមិនត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ខ្លួនដោយផ្ទុយពីឆន្ទៈខ្លួនឡើយ លើកលែងតែអាជ្ញាធរមានសមត្ថកិច្ចកំណត់តាមច្បាប់ និង នីតិវិធីដែលអាចអនុវត្តបានក្នុងវិស័យនេះថា ការបំបែកនេះគឺជាការចាំបាច់សំរាប់ផលប្រយោជន៍ល្អបំផុតរបស់កុមារ។ ការកំណត់នេះត្រូវបានធ្វើក្នុងល័ក្ខខ័ណ្ឌដែលត្រូវឱ្យមានការពិនិត្យឡើងវិញផ្នែកផ្លូវច្បាប់ ។ ការកំណត់បែបនេះអាចជាការចាំបាច់នៅក្នុងករណីពិសេសណាមួយ ដូចជាករណីដែលឪពុកម្តាយបំពាន ឬមិនសូវគិតដល់កុមារ ឬ ក៏ដូចជានៅក្នុងករណី ដែលឪពុកម្តាយរស់នៅបែកគ្នា ហើយទាមទារនូវការសំរេចចិត្តស្តីពីកន្លែងស្នាក់នៅរបស់កុមារ ។

២. នៅក្នុងរាល់កិច្ចពិភាក្សាទាក់ទិននឹងកថាខ័ណ្ឌ១នៃមាត្រានេះ ភាគីទាំងអស់ដែលមានការទាក់ទងក្នុងរឿងនេះ ត្រូវបានអនុញ្ញាតិឱ្យចូលរួមក្នុងកិច្ចពិភាក្សា ដើម្បីបញ្ចេញយោបល់របស់ខ្លួនបាន ។

៣. រដ្ឋជាភាគីគោរពសិទ្ធិកុមារដែលត្រូវបំបែកចេញពីឪពុក/ម្តាយណាម្នាក់ ឬពីឪពុកម្តាយទាំងពីរក្នុងការរក្សាទំនាក់ទំនងដោយផ្ទាល់ជាមួយឪពុកម្តាយឱ្យបានទៀតទាត់ លើកលែងតែប្រការនេះផ្ទុយនឹងផលប្រយោជន៍ល្អបំផុតរបស់កុមារ ។

៤. ពេលណាដែលការបែកចេញពីគ្នានេះបណ្តាលមកពីសកម្មភាពរបស់រដ្ឋជាភាគី ដូចជាការឃាត់ខ្លួន ដាក់ពន្ធនាគារ និរទេស ការបំបរបង់ ឬមរណភាព (រួមទាំងមរណភាព ដែលបណ្តាលមកពីហេតុអ្វីក៏ដោយនៅក្នុងពេលដែលបុគ្គលនោះស្ថិតនៅក្នុងកន្លែងឃាត់ខ្លួនរបស់រដ្ឋ) របស់អ្នកណា ម្នាក់ជាឪពុក ឬជាម្តាយ ឬក៏ទាំងឪពុកទាំងម្តាយ ឬក៏របស់កុមារនៅពេលមានសំណើ រដ្ឋជាភាគីត្រូវតែផ្តល់ដល់ឪពុកម្តាយដល់កុមារ ឬ ប្រសិនបើមានដល់សមាជិកផ្សេងទៀតនៃគ្រួសារនូវពតិមានសំខាន់ៗ ដែលទាក់ទិនទៅនឹងទីកន្លែងនៃសមាជិកគ្រួសារដែលបាត់ខ្លួន លើកលែងតែការផ្តល់ពតិមាននេះអាច

ធ្វើឱ្យប៉ះពាល់ដល់ផាសុកភាពរបស់កុមារ ។ ម្យ៉ាងទៀត រដ្ឋជាភាគីត្រូវធានាថា ការលើកឡើងនូវសំណើបែបនេះនឹងមិននាំជាផលវិបាកអាក្រក់អ្វីដល់សាមីជនដែលទាក់ទិននោះឡើយ ។

**មាត្រា ១០**

១. អនុលោមទៅតាមកាតព្វកិច្ចរបស់រដ្ឋជាភាគី ដែលមាននៅក្នុងមាត្រា៩ កថាខ័ណ្ឌ១ រាល់សំណើសុំរបស់កុមារ ឬឪពុកម្តាយ ដើម្បីចូល ឬចេញអំពីប្រទេសដើម្បីទៅជួបជុំគ្រួសារឡើងវិញនោះ រដ្ឋជាភាគីត្រូវតែទទួលដោះស្រាយដោយអនុគ្រោះប្រកបដោយមនុស្សធម៌ និង ឱ្យបានឆាប់រហ័សផង ។ ម្យ៉ាងវិញទៀត រដ្ឋជាភាគីត្រូវធានាថា ការស្នើសុំទាំងនេះ នឹងមិននាំមកនូវផលវិបាកអាក្រក់អ្វីដល់អ្នកស្នើសុំ និងដល់សមាជិកទាំងឡាយនៃគ្រួសារនេះឡើយ ។

២. កុមារដែលមានឪពុកម្តាយដែលរស់នៅរដ្ឋផ្សេងនោះ មានសិទ្ធិរក្សាចំណងមេត្រីភាពផ្ទាល់ខ្លួន និង ទាក់ទងផ្ទាល់ជាមួយឪពុកម្តាយរបស់ខ្លួន លើកលែងតែក្នុងកាលៈទេសៈជាពិសេសៗចេញ ។ ក្នុងទិសដៅនេះនិងដោយអនុលោមទៅតាមកាតព្វកិច្ចរបស់រដ្ឋជាភាគីដូចមានចែងនៅក្នុងមាត្រា៩កថាខ័ណ្ឌ១នោះរដ្ឋជាភាគីគោរពសិទ្ធិរបស់កុមារ ឬឪពុកម្តាយរបស់កុមារក្នុងការចាកចេញពីប្រទេសរួមបញ្ចូលទាំងប្រទេសរបស់ខ្លួនផង ក៏ដូចជាសិទ្ធិចូលមកក្នុងប្រទេសរបស់ខ្លួនវិញដែរ ។ សិទ្ធិចាកចេញពីប្រទេសអាចត្រូវខាឃាំងបានតែតាមលក្ខណៈច្បាប់ ហើយដែលចាំបាច់ដើម្បីការពារសន្តិសុខជាតិ របៀបរៀបរយសង្គម សុខភាពសាធារណៈ ឬ សីលធម៌ ឬ សិទ្ធិនិងសេរីភាពរបស់អ្នកឯទៀត ហើយដែលស្របគ្នាទៅនឹងសិទ្ធិឯទៀតៗដែលត្រូវបានទទួលស្គាល់ដោយអនុសញ្ញានេះ ។

**មាត្រា ១១**

១. រដ្ឋជាភាគីប្រកាន់យកវិធានការណ៍នានា ដើម្បីទប់មិនឱ្យមានការផ្ទេរចេញដោយខុសច្បាប់ និងការមិនត្រឡប់មកវិញរបស់កុមារដែលនៅឯបរទេស ។

២. ក្នុងទិសដៅនេះ រដ្ឋជាភាគីត្រូវជំរុញនូវការចុះកិច្ចព្រមព្រៀងជាទ្វេភាគី ឬ ជាពហុភាគី ឬ ចូលរួមទៅក្នុងកិច្ចព្រមព្រៀងនានាដែលមានស្រាប់មកហើយ ។

## មាត្រា ១២

១. រដ្ឋជាភាគីត្រូវធានាដល់កុមារណាដែលមានទស្សនៈផ្ទាល់ខ្លួន ឱ្យមានសេរីភាពក្នុងការបញ្ចេញទស្សនៈទាំងនោះនៅក្នុងវិស័យទាំងអស់ដែលទាក់ទិននឹងកុមារ ។ ទស្សនៈរបស់កុមារនឹងត្រូវបានយកទៅពិចារណាថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កុមារនោះ ។

២. ក្នុងទិសដៅនោះ កុមារត្រូវទទួលបាន ជាពិសេស នូវឱកាសបញ្ចេញយោបល់ខ្លួននៅក្នុងដំណើរការផ្នែកច្បាប់ និង ផ្នែករដ្ឋបាលទាំងឡាយណា ដែលទាក់ទិនដល់កុមារក្នុងលក្ខណៈមួយដែលស្របគ្នាទៅនឹងបញ្ញត្តិនីតិវិធីនៃច្បាប់ក្នុងប្រទេស ។ ការបញ្ចេញមតិនេះ អាចប្រព្រឹត្តទៅដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬ តាមស្ថាប័នសមស្របណាមួយ ។

## មាត្រា ១៣

១. កុមារមានសិទ្ធិក្នុងការសម្តែង (មតិ) ដោយសេរី ។ សិទ្ធិនេះរួមបញ្ចូលទាំងសេរីភាពក្នុងការស្វែងរកសេរីភាពក្នុងការទទួល និង សេរីភាពក្នុងការផ្សាយពត៌មាន និង ផ្សព្វផ្សាយគំនិតគ្រប់ប្រភេទដោយគ្មានគិតពីព្រំដែនអ្វីសោះឡើយ ទោះជាតាមការនិយាយស្តី សរសេរ ឬ តាមរយៈបណ្តាញឃោសនាផ្សេងៗណាទៀតក៏ដោយ ឱ្យតែស្របតាមការជ្រើសរើសរបស់កុមារ ។

២. ការប្រើប្រាស់សិទ្ធិនេះអាចស្ថិតនៅក្នុងកំហិតព្រំដែនមួយចំនួន ប៉ុន្តែការដាក់កំហិតនេះអាចប្រព្រឹត្តទៅបាន លុះត្រាណាដែលមានកំណត់ត្រឹមត្រូវតាមច្បាប់ ហើយចាំបាច់...

(ក) ចំពោះការគោរពសិទ្ធិ ហើយនិងកិត្តិនាមរបស់អ្នកដទៃ ឬ

(ខ) ដើម្បីការពារសន្តិសុខជាតិ ឬ របៀបរៀបរយសាធារណៈ ឬ សុខមាលភាពសាធារណៈ ឬ សីលធម៌ ។

## មាត្រា ១៤

១. រដ្ឋជាភាគីគោរពសិទ្ធិរបស់កុមារនៅក្នុងសេរីភាព ផ្នែកគំនិត មនសិការ និង សាសនា ។

២. រដ្ឋជាភាគីគោរពសិទ្ធិ និង កាតព្វកិច្ច របស់ឪពុកម្តាយ និង របស់អាណាព្យាបាលស្របច្បាប់ ក្នុងករណីដែលមានក្នុងការដឹកនាំកុមារនៅក្នុងការប្រើប្រាស់សិទ្ធិទាំងនេះ តាមរបៀបមួយដែលស្របទៅតាមការបណ្តុះបណ្តាលសមត្ថភាពរបស់កុមារនោះ ។

៣. សេរីភាពក្នុងការសំដែងអំពីសាសនា ឬសំដែងអំពីជំនឿរបស់ខ្លួនអាចដាក់ឱ្យមានកំរិតព្រំដែនបាន តែល្គឹកណាដែលមានកំណត់ត្រឹមត្រូវតាមច្បាប់ ហើយជាការចាំបាច់ដើម្បីការពារសុវត្ថិភាពសាធារណៈ សុខភាព និង សីលធម៌សាធារណៈ ឬ សិទ្ធិនិងសេរីភាពជាគ្រឹះទាំងឡាយរបស់អ្នកឯទៀតតែប៉ុណ្ណោះ ។

**មាត្រា ១៥**

១.រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងសេរីភាពចូលរួមជាមួយសមាគម និង សេរីភាពធ្វើការជួបប្រជុំដោយសន្តិវិធី ។

២. គ្មានការកំហិតណាមួយត្រូវបានដាក់ទៅលើសិទ្ធិទាំងនេះទេ លើកលែងតែការកំហិតនោះត្រូវបានកំណត់ដោយស្របទៅតាមច្បាប់ ហើយនិងចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីជាផលប្រយោជន៍ដល់សន្តិសុខសង្គម ឬ សុវត្ថិភាពសាធារណៈ របៀបរៀបរយសាធារណៈ ការការពារសុខភាព ឬ សីលធម៌សាធារណៈ ឬក៏ដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

**មាត្រា ១៦**

១. គ្មានកុមារណាម្នាក់ត្រូវបានទៅជាកម្មវត្ថុនៃការជ្រៀតជ្រែកដោយឯកចិត្ត ឬ ដោយខុសច្បាប់នៅក្នុងជីវិតជាឯកជនក្នុងគ្រួសារទីលំនៅ ឬ ការឆ្លងឆ្លើយគ្នា ព្រមទាំងការបំពារបំពានដោយខុសច្បាប់ទៅលើកិត្តិយស ឬ កិត្តិនាមរបស់ខ្លួនបានឡើយ ។

២. កុមារមានសិទ្ធិទទួលបានកិច្ចគាំពារផ្នែកផ្លូវច្បាប់ទល់នឹងការជ្រៀតជ្រែក និង បំពារបំពានទាំងអស់នេះ។

**មាត្រា ១៧**

រដ្ឋជាភាគីទទួលស្គាល់តួនាទីជាសំខាន់របស់បណ្តាញឃោសនាមហាជន ហើយធានាឱ្យកុមារទទួលនូវពត៌មាន និងឯកសារពីប្រភពប្លែកៗគ្នាផ្នែកជាតិ និងអន្តរជាតិ ជាពិសេស គឺពត៌មាន និងឯកសារដែលសំដៅដល់ការជំរុញផាសុកភាពផ្នែកសង្គម ស្មារតី និង សីលធម៌ ហើយនិងសុខភាពផ្នែករាងកាយ និង សតិបញ្ញា ។ ក្នុងទិសដៅនេះ រដ្ឋជាភាគីនឹង :

(ក) លើកទឹកចិត្តបណ្តាញឃោសនាមហាជន ឱ្យផ្សព្វផ្សាយពត៌មាននិងឯកសារដែលមានអត្ថប្រយោជន៍ផ្នែកសង្គម និង វប្បធម៌ដល់កុមារ និង ដោយស្របទៅតាមស្មារតីនៃមាត្រា២៩ ។

(ខ) លើកទឹកចិត្តកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ក្នុងផលិតកម្មក្នុងការផ្លាស់ប្តូរ និង ក្នុងការផ្សាយពត៌មាន និង ឯកសារទាំងនេះពីប្រភពប្លែកៗគ្នា ផ្នែកខាងវប្បធម៌ជាតិ និង អន្តរជាតិ ។

(គ) លើកទឹកចិត្តដល់ផលិតកម្ម និងការផ្សាយសៀវភៅសំរាប់កុមារ ។

(ឃ) លើកទឹកចិត្តបណ្តាញឃោសនាមហាជន ឱ្យមានការគិតគូរជាពិសេសដល់សេចក្តីត្រូវការផ្នែកភាសារបស់កុមារដែលជាក្រុមភាគតិច ឬដែលជាអ្នកស្រុកអាយ ។

(ង) លើកទឹកចិត្តដល់ការពង្រីកនូវគោលការណ៍ដឹកនាំសមស្រប ដើម្បីការពារកុមារតទល់នឹងពត៌មាន ព្រមទាំងឯកសារទាំងឡាយដែលប៉ះពាល់ដល់ផាសុខភាពរបស់កុមារ ដោយយោងទៅលើបទបញ្ញត្តិនៃមាត្រា ១៣ និង ១៨ ។

**មាត្រា ១៨**

១. រដ្ឋជាភាគីនឹងប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីធានាឱ្យមានការទទួលស្គាល់គោលការណ៍ដែលចែងថា ទាំងឪពុកទាំងម្តាយ សុទ្ធតែមានការទទួលខុសត្រូវរួមក្នុងការចិញ្ចឹមបីបាច់ ហើយនិងក្នុងការរីកចំរើនលូតលាស់របស់កុមារ ។ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់ បើសិនជាមានសុទ្ធតែមានការទទួលខុសត្រូវជាចំបងក្នុងការចិញ្ចឹមបីបាច់ និងក្នុងការរីកចំរើនលូតលាស់របស់កុមារ ។ ផលប្រយោជន៍ល្អបំផុតសំរាប់កុមារ គឺជាទិសដៅមូលដ្ឋានសំខាន់បំផុតរបស់ពួកគេ ។

២. ដើម្បីធានា និងជំរុញឡើងនូវសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ រដ្ឋជាភាគីផ្តល់នូវជំនួយឧបត្ថម្ភសមស្របដល់ឪពុកម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់ នៅក្នុងការបំពេញភារកិច្ចចិញ្ចឹមបីបាច់កុមារ ហើយត្រូវធានាធ្វើឱ្យរីកចំរើនដល់ស្ថាប័ន គ្រឿងឧបករណ៍ និង កិច្ចទំនុកបំរុងនានាដើម្បីថែទាំកុមារ ។

៣. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របនានា ដើម្បីធានាដល់កុមារដែលមានឪពុកម្តាយបំពេញការងារឱ្យទទួលបាននូវកិច្ចទំនុកបំរុងកុមារ និងឧបករណ៍ទាំងឡាយ ក្នុងការថែទាំទៅតាមល័ក្ខខ័ណ្ឌដែលខ្លួនត្រូវទទួលបាន ។

## មាត្រា ១៩

១. រដ្ឋជាភាគីប្រកាន់យកវិធានការសមស្របទាំងអស់ខាងផ្នែកច្បាប់ ផ្នែករដ្ឋបាល សង្គម និងផ្នែកអប់រំ ដើម្បីការពារកុមារតទល់នឹងទំរង់នៃភាពហិង្សាដែលប៉ះពាល់រាងកាយ ឬ គំនិតបញ្ញា ការមានរបួស ឬ ការបំពាន ការបោះបង់ចោល ឬ ការមិនគិតគូរដល់ការធ្វើបាប ឬ ការជិះជាន់ រួមទាំងការបំពារបំពានតាមផ្លូវភេទផង ក្នុងពេលដែលកុមារស្ថិតនៅក្រោមការ ចិញ្ចឹមបីបាច់របស់ឪពុក ឬម្តាយ (ឬទាំងឪពុកម្តាយ) អ្នកអាណាព្យាបាលស្របច្បាប់ ឬ កំបុគ្គលផ្សេងណាទៀតដែលទទួលខុសត្រូវក្នុងការថែទាំកុមារនោះ ។

២. ដើម្បីជាការសមរម្យ វិធានការការពារទាំងនេះគួររួមបញ្ចូលទាំងនីតិវិធីដ៏មានប្រសិទ្ធិភាពទាំងឡាយក្នុងការរៀបចំកម្មវិធីសង្គម ដើម្បីផ្តល់កិច្ចគាំទ្រជាចាំបាច់ចំពោះកុមារ និងចំពោះអ្នកទាំងឡាយណា ដែលទទួលការថែទាំកុមារ ព្រមទាំងចំពោះទំរង់ផ្សេងៗទៀតសំរាប់បង្ការ និងចំពោះការសំគាល់ភិនភាគ ចំពោះរបាយការណ៍ ចំពោះការសំអាង ការអង្កេត ការវិភាគពិនិត្យ និងតាមដានលើរាល់ករណីនៃការធ្វើបាបកុមារដែលបានលើកឡើងខាងលើនេះ ហើយក្នុងករណីសមស្របដើម្បីនីតិវិធីអន្តរាគមន៍ខាងផ្លូវច្បាប់ទៀតផង ។

## មាត្រា ២០

១. កុមារដែលប្រាសចាកជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ពីមជ្ឈដ្ឋានគ្រួសារខ្លួន ឬក៏ផលប្រយោជន៍ល្អបំផុតរបស់កុមារមិនអនុញ្ញាតឱ្យកុមារនោះរស់នៅក្នុងមជ្ឈដ្ឋាននេះបានត្រូវមានសិទ្ធិទទួលបានកិច្ចគាំពារ និងជំនួយឧបត្ថម្ភ ជាពិសេសពីរដ្ឋ ។

២. ដោយអនុលោមទៅតាមច្បាប់រដ្ឋរបស់ខ្លួន រដ្ឋជាភាគីត្រូវធានាដល់កុមារបែបនេះនូវកិច្ចថែទាំដែលអាចឆ្លាស់គ្នាបាន ។

៣. ក្រៅពីបែបឯទៀតៗ កិច្ចថែទាំបែបនេះរួមបញ្ចូលទាំងការដាក់ឱ្យទៅរស់នៅតាមគ្រួសារជាបែប **កាហ្វាឡា** តាមច្បាប់អ៊ីស្លាមជាបែបទទួលចិញ្ចឹមជាកូន ឬ បើសិនជាចាំបាច់ ការដាក់ឱ្យទៅនៅតាមស្ថាប័នថែទាំកុមារតាមលក្ខណៈពិសេសរៀងៗខ្លួន។ នៅក្នុងការជ្រើសរើសដំណោះស្រាយនេះ គេត្រូវយកចិត្តទុកដាក់លើភាពដែលចង់ឱ្យមានការចិញ្ចឹមថែទាំកុមារជានិច្ចនិរន្តរ៍ ហើយត្រូវយកចិត្តទុកដាក់ទៅលើប្រភពជាតិសាសន៍ សាសនា វប្បធម៌ និង ភាសារបស់កុមារ នោះផង ។

## មាត្រា ២១

រដ្ឋជាភាគីដែលទទួលស្គាល់ និងឬអនុញ្ញាតនូវប្រព័ន្ធសុំកូនចិញ្ចឹមត្រូវធានាថា ផលប្រយោជន៍ល្អបំផុតរបស់កុមារគឺជាមូលដ្ឋានចំបងនៅក្នុងបញ្ហានេះ ហើយត្រូវ...

(ក) ធានាថា ការសុំកូនចិញ្ចឹមត្រូវបានអនុញ្ញាតតែដោយអាជ្ញាធរមានសមត្ថកិច្ចមួយគត់ ដែលនឹងកំណត់ដោយអនុលោមទៅតាមច្បាប់និងនីតិវិធី ដែលអាចអនុវត្តបានក្នុងវិស័យនេះ និង ឈរលើមូលដ្ឋាននៃពត៌មានត្រឹមត្រូវ និង គួរឱ្យទុកចិត្តបាន ហើយនិងធានាថា ការសុំកូនចិញ្ចឹមនេះអាចអនុញ្ញាតបានដោយអាស្រ័យលើស្ថានភាពរបស់កុមារទាក់ទិនទៅនឹងឪពុកម្តាយ សាច់ញាតិ និងអ្នកអាណាព្យាបាលស្របច្បាប់ ហើយបើសិនជាចាំបាច់ បុគ្គលទាំងឡាយដែលមានទាក់ទិនត្រូវបានផ្តល់ការយល់ព្រមរបស់ខ្លួនលើការសុំកូនចិញ្ចឹមនេះ ដោយមានការយល់ដឹងច្បាស់លាស់ និងក្រោយពីបានទទួលការបំភ្លឺជាចាំបាច់រួចមក ។

(ខ) ទទួលស្គាល់ថាការសុំកូនចិញ្ចឹមជាអន្តរប្រទេសអាចចាត់ទុកជាមធ្យោបាយចំលាស់ (alternative means) មួយនៃការថែទាំកុមារ បើសិនជានៅក្នុងប្រទេសដើមកំណើតរបស់ខ្លួន កុមារមិនអាចទៅរស់នៅតាមគ្រួសារ ឬ ក្នុងគ្រួសារដែលទទួលចិញ្ចឹមកូន ឬមិនអាចទទួលបាននូវការថែទាំឱ្យបានសមស្របទេនោះ ។

(គ) ធានាឱ្យកុមារដែលត្រូវគេសុំយកទៅចិញ្ចឹមនៅឯប្រទេសផ្សេង ទទួលបាននូវកិច្ចការពារ និង បទដ្ឋានដូចគ្នាទៅនឹងកិច្ចការពារ ហើយនិងបទដ្ឋាននានា ដែលមាននៅក្នុងប្រទេសនោះ ។

(ឃ) ប្រកាន់យកនូវវិធានការសមស្របនានាដើម្បីធានាថា នៅក្នុងករណីសុំកូនជាអន្តរប្រទេស ការផ្តល់កូននេះពុំត្រូវជាកត្តាបង្កើតឱ្យមានប្រាក់ចំណូលមិនត្រឹមត្រូវមួយដល់រាល់បុគ្គលដែលមានការទាក់ទិនក្នុងរឿងនេះឡើយ ។

(ង) ជំរុញទិសដៅនៃមាត្រានេះ ក្នុងករណីណាដែលសមស្របដោយការចុះកិច្ចព្រមព្រៀង ឬកិច្ចសំរុះសំរួលជាទ្វេភាគី ឬជាពហុភាគី ហើយនៅក្នុងក្របខ័ណ្ឌនេះប្រឹងប្រែងធានាឱ្យបានថា ការយកកុមារទៅឱ្យគេចិញ្ចឹមនៅឯប្រទេសក្រៅត្រូវចាត់ចែងដោយអាជ្ញាធរ ឬអង្គការមានសមត្ថកិច្ច ។

## មាត្រា ២២

១. រដ្ឋជាភាគីប្រកាន់យកនូវវិធានការសមស្របទាំងឡាយ ដើម្បីធានាឱ្យកុមារដែលស្វះស្វែងរក ឋានះជាអ្នកភៀសខ្លួន ឬដែលត្រូវចាត់ទុកជាអ្នកភៀសខ្លួនដោយអនុលោមទៅតាមបញ្ញត្តិនៃនីតិវិធីរបស់ច្បាប់អន្តរជាតិ និង ជាតិដែលអាចអនុវត្តនៅក្នុងវិស័យនេះ ទោះជាកុមារនោះតែម្នាក់ឯង ឬដោយមានឪពុក ម្តាយ ឬអ្នកដទៃទៀតមកជាមួយក្តី ក៏ឱ្យកុមារទទួលបាននូវកិច្ចគាំពារ និង ជំនួយឧបត្ថម្ភមនុស្សធម៌ដ៏សមស្របក្នុងការប្រើប្រាស់សិទ្ធិដែលអាចអនុវត្តបានក្នុងប្រការនេះ ហើយដែលមានចែងនៅក្នុងអនុសញ្ញានេះ និង៖ នៅក្នុងឯកសារអន្តរជាតិនានាឯទៀត ស្តីពីសិទ្ធិមនុស្ស ឬមនុស្សធម៌ដែលសាមុីរដ្ឋបានចូលជាភាគី ។

២. ក្នុងទិសដៅនេះ ហើយបើសិនជាយល់ថាចាំបាច់ រដ្ឋជាភាគីនឹងផ្តល់កិច្ចសហប្រតិបត្តិការរបស់ខ្លួនដល់កិច្ចប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ និងរាល់អង្គការអន្តររដ្ឋាភិបាល ឬ អង្គការមិនមែនរដ្ឋាភិបាលមានសមត្ថកិច្ចទាំងឡាយ ដែលធ្វើសហការជាមួយអង្គការសហប្រជាជាតិ ដើម្បីគាំពារ និង ជួយឧបត្ថម្ភកុមារទាំងនេះ ហើយនិងស្វែងរកឪពុកម្តាយ ឬក៏សមាជិកផ្សេងទៀតនៃគ្រួសាររបស់កុមារភៀសខ្លួនទាំងអស់ ដើម្បីស្រង់យកពតិមានចាំបាច់សំរាប់ជួយឱ្យកុមារបានជួបជុំ

ជាមួយគ្រួសារខ្លួនឡើងវិញ ។ ដូចមានចែងក្នុងអនុសញ្ញានេះស្រាប់ ក្នុងករណីដែលរកមិនឃើញឪពុកម្តាយ ឬ សមាជិកផ្សេងទៀតនៃគ្រួសារនោះទេកុមារត្រូវទទួលបានកិច្ចគាំពារដូចគ្នានឹងកុមារដែលបានបែកចេញជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នពីមជ្ឈដ្ឋានគ្រួសារខ្លួន ទោះជាមូលហេតុអ្វីក៏ដោយ ។

## មាត្រា ២៣

១. រដ្ឋជាភាគីទទួលស្គាល់ថា កុមារដែលមានពិការភាពផ្នែកសតិបញ្ញា ឬរាងកាយ គួរទទួលបាននូវជីវភាពរស់នៅមួយសមរម្យ និង ពេញលេញក្នុងលក្ខខ័ណ្ឌមួយដែលអាចធានាឱ្យមានភាពថ្លៃថ្នូរអាចជំរុញឱ្យចេះទទួលខុសត្រូវលើខ្លួនឯង ហើយនិងជួយសំរួលឱ្យកុមារអាចចូលរួមយ៉ាងសកម្មក្នុងសហគមន៍ ។

២. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការទទួលបាននូវការថែទាំពិសេស ហើយអាស្រ័យទៅតាមសម្បត្តិធនធានដែលមាន រដ្ឋត្រូវជួយលើកទឹកចិត្ត និងធានានូវការលាតសន្ធឹងនូវជំនួយឧបត្ថម្ភឱ្យដល់កុមារ ឬអ្នកថែទាំកុមារទាំងឡាយណាដែលមានលក្ខណៈត្រូវទទួលបាន បើសិនជាសំណើ ហើយដែលសំណើនោះសមស្របទៅនឹងស្ថានភាពរបស់កុមារ និង របស់ឪពុកម្តាយ ឬអ្នកទទួលខុសត្រូវថែទាំកុមារនោះ ។

៣. ដោយទទួលស្គាល់នូវសេចក្តីត្រូវការ ជាពិសេសរបស់កុមារពិការ ជំនួយឧបត្ថម្ភដែលបានផ្តល់ដោយអនុលោមទៅតាមកថាខ័ណ្ឌ២ នៃមាត្រានេះ ត្រូវតែផ្តល់ឱ្យដោយឥតគិតថ្លៃនៅរាល់ ពេលណាដែលមានលទ្ធភាព ដោយយោងទៅលើធនធានហិរញ្ញវត្ថុរបស់ឪពុកម្តាយ ឬរបស់អ្នកផ្សេងទៀតដែលទទួលថែទាំកុមារ ហើយត្រូវគិតគូរយ៉ាងណាដើម្បីឱ្យកុមារពិការអាចឈោងចាប់យកបាន និងទទួលបានដោយផ្ទាល់នូវការអប់រំ ការហ្វឹកហ្វឺន កិច្ចទំនុកបំរុងផ្នែកសុខាភិបាល កិច្ចទំនុកបំរុងខាងការសំរួលសម្បទានឡើងវិញ ការរៀបចំខ្លួនដើម្បីបំពេញការងារ និងលទ្ធភាពលំហែកាយ ក្នុងលក្ខណៈមួយដែលអាចនាំឱ្យកុមារអាចរួមរស់បានយ៉ាងពេញលេញបំផុតនៅក្នុងសង្គម និង អាចចំរើនលូតលាស់ខាងផ្នែកបុគ្គលខ្លួនផ្ទាល់ រួមបញ្ចូលទាំង ការរីកចំរើនផ្នែកវប្បធម៌ និងស្មារតីផង ។

៤. នៅក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ រដ្ឋជាភាគីត្រូវជំរុញឱ្យមានការផ្លាស់ប្តូរគ្នានូវពត៌មានសមស្របដែលទាក់ទងទៅលើវិស័យកិច្ចបង្កា និង ការពារសុខភាព ហើយនិងការ

ព្យាបាលផ្នែកវេជ្ជសាស្ត្រ ផ្នែកចិត្តសាស្ត្រ និងការព្យាបាលដំណើរសរីរាង្គដល់កុមារពិការ ដោយរួមបញ្ចូលទាំងការផ្សាយ និងការអនុញ្ញាតឱ្យទទួលបាននូវពត៌មានដែលទាក់ទិនទៅនឹងវិធីសំរួលសម្បទានឡើងវិញ ការងារអប់រំ និង ការហ្វឹកហ្វឺនវិជ្ជាជីវៈ ក្នុងទិសដៅអាចឱ្យរដ្ឋជាភាគីបង្កើនសមត្ថភាព និងថ្វីដៃរបស់ខ្លួន ព្រមទាំងដើម្បីបទពិសោធន៍របស់ខ្លួននៅក្នុងវិស័យនេះអាចរីកទូលំទូលាយបាន ។ នៅក្នុងចំណុចនេះ គេត្រូវយកចិត្តទុកដាក់ ជាពិសេសលើសេចក្តីត្រូវការនៃប្រទេសដែលកំពុងលូតលាស់ ។

## មាត្រា ២៤

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការទទួលបាននូវកំរិតសុខភាពដ៏ខ្ពស់បំផុតដែលអាចធ្វើទៅបាន ហើយនិងទទួលបាននូវភាពងាយស្រួលក្នុងការព្យាបាលជម្ងឺ និង ស្តារសុខភាព ។ រដ្ឋជាភាគីនឹងប្រឹងប្រែងដើម្បីធានាឱ្យបានថា គ្មានកុមារណាម្នាក់ត្រូវបាត់បង់សិទ្ធិទទួលយកកិច្ចទំនុកបំរុងសុខភាពនេះឡើយ ។

២. រដ្ឋជាភាគីប្រឹងប្រែងធ្វើឱ្យបានសំរេចទាំងស្រុងនូវសិទ្ធិនេះ ហើយជាពិសេសត្រូវប្រកាន់យកវិធានការសមស្របទាំងពួងដើម្បី :

(ក) បន្ថយមរណភាពនៃទារក និងកុមារ

(ខ) ធានាផ្តល់ដល់គ្រប់កុមារទាំងអស់នូវជំនួយវេជ្ជសាស្ត្រ និង ការថែទាំសុខភាព ដោយផ្តោត ជាពិសេសលើការថែទាំសុខភាពបឋម

(គ) ដោយរួមទាំងនៅក្នុងក្របខ័ណ្ឌនៃការថែទាំសុខភាពបឋមផង កំចាត់រោគ និង ការហូបចុក មិនគ្រប់គ្រាន់ តាមរយៈការអនុវត្តន៍តិចណូឡូស៊ីដែលមានស្រាប់ ហើយនិងតាមរយៈការផ្គត់ផ្គង់ស្បៀងដែលមានធាតុចិញ្ចឹមគ្រប់គ្រាន់ និងទឹកហូបស្អាត ដោយមានការប្រយ័ត្នប្រយែងទៅលើគ្រោះថ្នាក់ និងភាពប្រថុយប្រថាន ដែលបណ្តាលមកពីភាពក្រខ្វក់នៃបរិស្ថានផង ។

(ឃ) ធានានូវការថែទាំសុខភាពដល់មាតា នៅមុន និងក្រោយពេលសំរាលកូន ។

(ង) ធានាធ្វើយ៉ាងណាឱ្យគ្រប់ក្រុមក្នុងសង្គម ជាពិសេស គឺឪពុកម្តាយ និង កុមារទទួលបានពត៌មានស្តីពីសុខភាព និង ការចិញ្ចឹមកុមារពីផលប្រយោជន៍នៃការ

បំបៅកូន ពីអនាម័យ និង ពីការសំអាតមជ្ឈដ្ឋាន ហើយនិងការបង្ការគ្រោះថ្នាក់ ព្រមទាំងផ្តល់នូវការគាំទ្រដើម្បីឱ្យអ្នកទាំងនោះអាចប្រើប្រាស់ប្រកបដោយ ផលប្រយោជន៍បាននូវចំណេះដឹងជាមូលដ្ឋាន ។

(ច) ពង្រីកការថែទាំសុខភាពជាបង្ការ (វិធីបង្ការរោគ) ផ្តល់មតិណែនាំដល់ឪពុក ម្តាយ និង ផ្តល់ការអប់រំ ហើយនិងកិច្ចទំនុកបំរុងនានាក្នុងវិស័យផែនការនីយ កម្មគ្រួសារ (Family Planning) ។

៣. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការដ៏មានប្រសិទ្ធិភាព និង ដ៏សមស្របក្នុងទិសដៅ លុបបំបាត់រាល់ទម្លាប់ប្រព្រឹត្តដែលអាចប៉ះពាល់ដល់សុខភាពកុមារ ។

៤. រដ្ឋជាភាគីសន្យាថានឹងជំរុញ ហើយនិងលើកទឹកចិត្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុង ទិសដៅធ្វើឱ្យបានសំរេចមួយកំរិតម្តងៗរហូតដល់បានសំរេចទាំងស្រុងនូវសិទ្ធិដែលត្រូវបានទទួលស្គាល់ នៅក្នុងមាត្រានេះ ។ ក្នុងប្រការនេះ សេចក្តីត្រូវការរបស់ប្រទេសកំពុងលូតលាស់ ត្រូវបានយកចិត្តទុក ដាក់ជាពិសេស ។

## មាត្រា ២៥

រដ្ឋជាភាគីទទួលស្គាល់ថា កុមារដែលអាជ្ញាធរមានសមត្ថកិច្ចបានចាត់ចែងទុកដាក់ ដើម្បីឱ្យ មានការថែទាំ មានកិច្ចគាំពារ ឬការព្យាបាលផ្នែករាងកាយ ឬសតិបញ្ញានោះ មានសិទ្ធិទទួលបាន នូវការត្រួតពិនិត្យជាទៀងទាត់លើការព្យាបាលដែលត្រូវបានផ្តល់ទៅឱ្យខ្លួន ព្រមទាំងមានការត្រួត ពិនិត្យទៅលើកាលៈទេសៈផ្សេងទៀតនៃការទុកដាក់កុមារនោះផងដែរ ។

## មាត្រា ២៦

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូប ក្នុងការទទួលគុណប្រយោជន៍ពីសន្តិសុខ សង្គម ដោយរួមទាំងកិច្ចធានារ៉ាប់រងសង្គមផង ហើយនិងប្រកាន់យកវិធានការចាំបាច់ទាំងឡាយ ដើម្បីធានាធ្វើឱ្យបានសំរេចទាំងស្រុងនូវសិទ្ធិនេះ ដោយយោងទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួនផ្ទាល់ ។

២. គុណប្រយោជន៍ទាំងឡាយត្រូវផ្តល់ឱ្យកុមារ តាមការសមរម្យដោយយោងទៅលើ ធនធាន និងស្ថានភាពរបស់កុមារនោះ និងអ្នកដែលទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់កុមារ ព្រម

ទាំងយោងទៅលើចំណុចថ្លឹងថ្លែងផ្សេងទៀតដែលទាក់ទិនទៅនឹងសំណើសុំគុណប្រយោជន៍ទាំងឡាយឯទៀតដែលកុមារនោះ ស្នើឡើងដោយខ្លួនឯង ឬដែលអ្នកដទៃស្នើសុំក្នុងនាមកុមារនោះ ។

## មាត្រា ២៧

១. រដ្ឋជាភាគីទទួលស្គាល់ថា កុមារគ្រប់រូបសុទ្ធតែមានសិទ្ធិក្នុងការមានកំរិតជីវភាពរស់នៅមួយគ្រប់គ្រាន់ ដើម្បីឱ្យមានការរីកចំរើនលូតលាស់ផ្នែករាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់ខ្លួនបាន ។

២. ដោយយោងទៅតាមកំរិតនៃលទ្ធភាព និង សមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួន ឪពុកម្តាយឬអ្នកដទៃទៀតដែលទទួលខុសត្រូវលើកុមារមានភារកិច្ចទទួលខុសត្រូវជាចំបង ក្នុងការធានានូវកំរិតជីវភាពរស់នៅ មួយដែលចាំបាច់ដល់ការចំរើនលូតលាស់របស់កុមារ ។

៣. ដោយយោលទៅតាមស្ថានភាពជាតិ និង ក្នុងកំរិតមធ្យោបាយរបស់ខ្លួន រដ្ឋជាភាគីត្រូវប្រកាន់យករាល់វិធានការសមស្រប ដើម្បីជួយឧបត្ថម្ភដល់ឪពុកម្តាយ ឬ ដល់អ្នកដែលមានការទទួលខុសត្រូវលើកុមារក្នុងការអនុវត្តន៍សិទ្ធិនេះ ហើយនៅក្នុងពេលដែលមានសេចក្តីត្រូវការរដ្ឋត្រូវផ្តល់ជំនួយឧបត្ថម្ភផ្នែកសម្ភារៈ ហើយនិងកម្មវិធីគាំទ្រទាំងឡាយ ជាពិសេសនៅក្នុងបញ្ហាហូបចុកសំលៀកបំពាក់ និងផ្ទះសម្បែង ។

៤. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របនានា ដើម្បីធានាឱ្យកុមារបានទទួលសោធន អាហារកិច្ច ( ប្រាក់ចិញ្ចឹមជីវិតដែលប្តី ឬប្រពន្ធត្រូវឧបត្ថម្ភដល់ភាគីម្ខាងទៀត ឬដល់កូននៅពេលដែលលែងលះគ្នា) ពីឪពុកម្តាយ ឬពីអ្នកដទៃផ្សេងទៀតដែលទទួលបន្ទុកផ្នែកហិរញ្ញវត្ថុលើកុមារទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ។ ជាពិសេសនៅពេលដែលអ្នកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុលើកុមារនេះរស់នៅក្នុងរដ្ឋផ្សេងទៀត រដ្ឋទាំងសង្ខាងត្រូវជំរុញឱ្យមានការចូលរួមជាភាគីនៅក្នុងកិច្ចព្រមព្រៀងជាអន្តរជាតិ ឬ ក៏ចុះជាកិច្ចព្រមព្រៀងរបៀបនេះ ក៏ដូចជាការសំរុះសំរួលនានាដែលសមស្រប ( ក្នុងការផ្ទេរប្រាក់ឧបត្ថម្ភបែបនេះមកឱ្យកុមារ) ។

## មាត្រា ២៨

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការរៀនសូត្រ ហើយក្នុងទិសដៅធ្វើឱ្យបានសំរេចជាលំដាប់នូវសិទ្ធិនេះ និងដោយឈរលើមូលដ្ឋាននៃលទ្ធភាពស្មើគ្នា ជាពិសេសគឺរដ្ឋជាភាគី ត្រូវ...

(ក) ធ្វើឱ្យការសិក្សាកំរិតបឋមសិក្សាមានលក្ខណៈជាកាតព្វកិច្ច ហើយឥតបង់ថ្លៃសំរាប់គ្រប់ៗគ្នា

(ខ) លើកទឹកចិត្តដល់ការពង្រីកទំរង់នានានៃផ្នែកមធ្យមសិក្សា រួមទាំងផ្នែកចំណេះទូទៅទាំងផ្នែកវិជ្ជាជីវៈ បើកជូននិងចំហរយ៉ាងទូលំទូលាយសំរាប់កុមារគ្រប់ៗរូប ហើយនិងប្រកាន់យកនូវវិធានការសមស្របនានាដូចជាការបញ្ចូលការរៀនសូត្រដោយឥតបង់ថ្លៃ ព្រមទាំងការផ្តល់ជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុក្នុងករណីដែលមានសេចក្តីត្រូវការជាដើម

(គ) តាមគ្រប់មធ្យោបាយដែលមាន ធានាឱ្យគ្រប់ៗគ្នាអាចចូលរៀនក្នុងឧត្តមសិក្សាបានអាស្រ័យ ដោយសមត្ថភាពរបស់គេម្នាក់ៗ

(ឃ) បើកជូន និង ចំហរយ៉ាងទូលំទូលាយនូវពត៌មាន និង ការណែនាំតំរង់ទិសផ្នែកអប់រំព្រមទាំងផ្នែកវិជ្ជាជីវៈដល់គ្រប់កុមារទាំងអស់

(ង) ប្រកាន់យកវិធានការនានាដើម្បីលើកទឹកចិត្តការរៀនសូត្រជាទៀងទាត់នៅក្នុងសាលា ហើយនិងដើម្បីបន្ថយអត្រាបោះបង់ចោលការសិក្សា ។

២. រដ្ឋជាភាគីប្រកាន់យកនូវរាល់វិធានការសមស្រប ដើម្បីធានាថា វិន័យរបស់សាលាត្រូវបានដាក់ចុះក្នុងលក្ខណៈមួយដែលស្របគ្នាទៅភាពថ្លៃថ្នូរជាមនុស្សរបស់កុមារ ហើយនិងស្របទៅតាមអនុសញ្ញានេះ ។

៣. រដ្ឋជាភាគីជំរុញ និងលើកទឹកចិត្តកិច្ចសហប្រតិបត្តការអន្តរជាតិនៅក្នុងវិស័យនានាដែលទាក់ទិនដល់ការអប់រំ ជាពិសេសក្នុងទស្សនៈរួមចំណែកដើម្បីលុបបំបាត់ភាពល្ងង់ខ្លៅ និងអនក្ខរភាពនៅទូទាំងពិភពលោកហើយសំរួលដល់ការឈោងចាប់(យកឱ្យបាន)នៅចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងតិចនិច ហើយនិងវិធីបង្រៀនសម័យទំនើប ។ ក្នុងចំណុចនេះត្រូវយកចិត្តទុកដាក់ជាពិសេសដល់សេចក្តីត្រូវការរបស់ប្រទេសដែលកំពុងលូតលាស់ ។

## មាត្រា ២៩

១. រដ្ឋជាភាគីឯកភាពថា ការអប់រំកុមារត្រូវតែឆ្ពោះទៅរក :

(ក) ការចំរើនលូតលាស់នៃបុគ្គលភាពរបស់កុមារ ហើយនិងការចំរើនលូតលាស់យ៉ាងពេញទំហឹងនូវទេព្យកោសល្យ ព្រមទាំងសម្បទានផ្នែកសតិបញ្ញា និង ផ្នែករាងកាយរបស់កុមារ ។

(ខ) ការចំរើនលូតលាស់នៃការគោរពសិទ្ធិមនុស្ស ហើយនិងសេរីភាពជាគ្រឹះទាំងឡាយព្រមទាំងការគោរពរាល់គោលការណ៍ទាំងឡាយ ដែលមានចារទុកនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ។

(គ) ការចំរើនលូតលាស់នៃការគោរពឪពុកម្តាយរបស់ខ្លួន អត្តសញ្ញាណ វប្បធម៌ ភាសា និង តម្លៃរបស់ខ្លួនផ្ទាល់ ការគោរពប្រទេសដែលជាដើមកំណើតខ្លួន ហើយនិងអារ្យធម៌នានាដែលខុសប្លែកពីអារ្យធម៌របស់ខ្លួនផ្ទាល់ ។

(ឃ) ការត្រៀមបំរុងកុមារឱ្យចេះដឹកនាំជីវិតដែលប្រកបដោយការទទួលខុសត្រូវនៅក្នុងសង្គមមានសេរីភាព, ក្នុងស្មារតីនៃការយោគយល់គ្នា សន្តិភាព អនុគ្រោះភាពស្មើគ្នារវាងភេទ ហើយនិងមិត្តភាពរវាងប្រជាជនពូជសាសន៍ជាតិ ក្រុមសាសនានានា ហើយនិងរវាងបុគ្គលទាំងឡាយដែលមានប្រភពជាអ្នកស្រុកអាយ ។

(ង) ការចំរើននៃការគោរពដល់បរិស្ថានធម្មជាតិ ។

២. គ្មានបទបញ្ញាណាមួយនៃមាត្រានេះ ឬមាត្រា២៨ត្រូវបានយកមកបកស្រាយតាមរបៀបណាមួយ ដែលប៉ះពាល់ទៅលើសេរីភាពរបស់បុគ្គល ឬរបស់ស្ថាប័នដែលបង្កើត និងដឹកនាំគ្រឹះស្ថាននានានោះឡើយ ក្នុងល័ក្ខខ័ណ្ឌដែលថាគោលការណ៍ទាំងឡាយដែលបានចែងនៅក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ ត្រូវបានគោរព ហើយការអប់រំដែលត្រូវបានបង្ហាត់បង្ហាញនៅក្នុងគ្រឹះស្ថាននោះត្រឹមត្រូវទៅតាមបទដ្ឋានអប្បបរមាដែលកំណត់ឡើងដោយរដ្ឋ ។

## មាត្រា ៣០

នៅក្នុងរដ្ឋដែលមានក្រុមភាគតិចផ្នែកពូជសាសន៍ សាសនា ឬភាសា ឬក៏មានពួកបុគ្គលដែលជាអ្នកស្រុកអាយ កុមារដែលស្ថិតនៅក្នុងក្រុមភាគតិចបែបនេះ ឬក៏ដែលជាអ្នកស្រុកអាយនោះ មិន

ត្រូវបានដកហូតសិទ្ធិមានជីវភាព វប្បធម៌ ផ្សព្វផ្សាយ និងគោរពសាសនា ឬប្រើប្រាស់ភាសារបស់ខ្លួនផ្ទាល់ រួមជាមួយនឹងសមាជិកឯទៀតនៃសហគមន៍របស់ខ្លួនឡើយ ។

## មាត្រា ៣១

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារ ក្នុងការសំរាក និងកំសាន្ត ក្នុងការលេងល្បែងកំសាន្ត និង សកម្មភាពលំហែ ដែលសមស្របទៅតាមអាយុរបស់កុមារ ហើយនិងសិទ្ធិចូលរួម ដោយសេរីនៅក្នុងជីវភាពវប្បធម៌ និងសិល្បៈ ។

២. រដ្ឋជាភាគីត្រូវប្រកាន់យករាល់វិធានការផ្នែកច្បាប់ ផ្នែករដ្ឋបាល សង្គម និង ផ្នែកអប់រំ ដើម្បីធានាដល់ការអនុវត្តន៍មាត្រានេះ ។ ក្នុងទិសដៅនេះ និង ដោយយោងលើបទបញ្ញត្តិនៃឯកសារអន្តរជាតិឯ ទៀតៗដែលទាក់ទិននោះ រដ្ឋជាភាគីត្រូវ ជាពិសេស :

(ក) កំណត់អាយុអប្បបរមា ឬរាល់អាយុអប្បបរមាសំរាប់ទទួលឱ្យចូលធ្វើការ

(ខ) កំណត់នូវបញ្ញត្តិសមស្របស្តីពីម៉ោងពេល និងល័ក្ខខ័ណ្ឌការងារ

(គ) កំណត់ឡើងនូវទោស និងទណ្ឌកម្មផ្សេងៗទៀតដ៏សមស្រប ដើម្បីធានាឱ្យមានប្រសិទ្ធិភាព ដល់ការអនុវត្តន៍មាត្រានេះ ។

## មាត្រា ៣២

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការទទួលបានកិច្ចគាំពារតទល់ការជិះជាន់សេដ្ឋកិច្ច ហើយនិងបំពេញរាល់ការងារណាដែលអាចប៉ះពាល់ ឬ ដែលអាចរំខានដល់ការអប់រំរបស់កុមារ ឬ ដែលអាចបំផ្លាញសុខភាព ឬ ការរីកចំរើនខាងរាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ ។

២. រដ្ឋជាភាគី នឹងប្រកាន់យករាល់វិធានការណ៍ច្បាប់ រដ្ឋបាល សង្គម និងអប់រំ ដើម្បីធានាដល់ការអនុវត្តមាត្រានេះ ។ ក្នុងទិសដៅនេះ និងដោយយោងទៅលើបទបញ្ញត្តិនៃឯកសារអន្តរជាតិឯទៀតៗដែល ទាក់ទិននោះ រដ្ឋជាភាគី ជាពិសេស :

(ក) កំណត់អាយុអប្បបរមា ឬរាល់អាយុអប្បបរមាសំរាប់ទទួលឱ្យចូលធ្វើការ.

(ខ) កំនត់នូវបញ្ញត្តិសមស្របស្តីពីម៉ោងពេល និងល័ក្ខខ័ណ្ឌការងារ

(គ) កំណត់ឡើងនូវទោស និងទណ្ឌកម្មផ្សេងៗទៀតដែលសមស្របដើម្បីធានាដល់ការអនុវត្តន៍ ប្រកបដោយប្រសិទ្ធិភាព នូវមាត្រានេះ ។

**មាត្រា ៣៣**

រដ្ឋជាភាគីប្រកាន់យកវិធានការសមស្រប រួមបញ្ចូលទាំងវិធានការផ្នែកច្បាប់ ផ្នែករដ្ឋបាលសង្គម និងផ្នែកអប់រំផង ដើម្បីការពារកុមារទល់នឹងការប្រើប្រាស់ខុសច្បាប់នូវគ្រឿងញៀនស្រវឹង និង សារជាតិទាក់ទងទៅនឹងចិត្តសាស្ត្រ ដូចមានកំណត់នៅក្នុងសន្ធិសញ្ញាអន្តរជាតិនានាដែលទាក់ទងទៅនឹងបញ្ហានេះ និង ដើម្បីបង្ការការប្រើប្រាស់កុមារនៅក្នុងការផលិត និងជួញដូរដោយខុសច្បាប់នូវប្រភេទសារជាតិទាំងនេះ ។

**មាត្រា ៣៤**

រដ្ឋជាភាគីសន្យាថា នឹងការពារកុមារតទល់នឹងរាល់ទំរង់នៃការជិះជាន់ផ្លូវភេទ និងការបំពារបំពានផ្លូវភេទ ។ ក្នុងទិសដៅនេះ រដ្ឋជាភាគីប្រកាន់យកជាពិសេសនូវវិធានការសមស្របទាំងអស់ក្នុងក្របខ័ណ្ឌជាតិ ក្របខ័ណ្ឌទ្វេភាគី និងក្របខ័ណ្ឌពហុភាគី ដើម្បីខាយាំង (កុំឱ្យមាន) :

(ក) ការញុះញង់ ឬការបង្ខិតបង្ខំកុមារឱ្យប្រព្រឹត្តសកម្មភាពផ្លូវភេទដោយខុសច្បាប់.

(ខ) ការប្រើប្រាស់កុមារជាផ្លូវអាជីវកម្មក្នុងពេស្យាកម្ម ឬរាល់ការប្រព្រឹត្តផ្លូវភេទដោយខុសច្បាប់

(គ) ការប្រើប្រាស់កុមារជាផ្លូវអាជីវកម្មនៅក្នុងការសំដែង ឬផលិតចេញជាសម្ភារៈផ្នែកកាមសាស្ត្រអាសគ្រាម ។

**មាត្រា ៣៥**

រដ្ឋជាភាគីនឹងប្រកាន់យកនូវរាល់វិធានការសមស្របក្នុងក្របខ័ណ្ឌជាតិ ក្របខ័ណ្ឌទ្វេភាគីឬពហុភាគី ដើម្បីខាយាំងការចាប់ពង្រាត់ ការលក់ ឬជួញដូរកុមារ ទោះជាក្នុងទិសដៅអ្វីឬទំរង់អ្វីក៏ដោយ ។

**មាត្រា ៣៦**

រដ្ឋជាភាគីត្រូវការពារតទល់នឹងរាល់ទំរង់ផ្សេងទៀតនៃការចំរាញ់យកផលពីកុមារ ដែលប៉ះពាល់ ដល់គ្រប់ទិដ្ឋភាពនៃផាសុខភាពរបស់កុមារ ។

## មាត្រា ៣៧

រដ្ឋជាភាគីត្រូវធានាថា ៖

(ក) គ្មានកុមារណាម្នាក់ត្រូវរងទណ្ឌកម្ម ឬទទួលការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែល ឃោរឃៅអមនុស្សធម៌ ឬ ដែលនាំឱ្យបាត់បង់តំលៃជាមនុស្សឡើយ ។ ការប្រហារជីវិត និងការឃុំឃាំងអស់មួយជីវិតដោយគ្មានលទ្ធភាពដោះលែងមិនត្រូវអនុវត្តចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តដោយបុគ្គលដែលមានអាយុតិចជាងដប់ប្រាំបីឆ្នាំឡើយ

(ខ) គ្មានកុមារណាម្នាក់ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬដោយតាមអំពើចិត្តនោះឡើយ ។ ការចាប់ខ្លួនឃុំខ្លួន ឬដាក់ពន្ធនាគារចំពោះកុមារ ត្រូវតែស្របតាមច្បាប់ ហើយត្រូវបានប្រើសំរាប់តែជាវិធានការចុងក្រោយ ហើយសំរាប់តែក្នុងរយៈពេលយ៉ាងខ្លីដោយសមស្រប

(គ) រាល់កុមារដែលត្រូវបានដកហូតសេរីភាព ត្រូវតែទទួលបាននូវការទុកដាក់មួយប្រកបដោយមនុស្សធម៌ និង ដោយការគោរពចំពោះភាពថ្លៃថ្នូររបស់បុគ្គលមនុស្សដែលមិនអាចកាត់ផ្តាច់បាន ហើយក្នុងលក្ខណៈមួយដែលយោងទៅតាមសេចក្តីត្រូវការរបស់បុគ្គលនៅក្នុងអាយុនោះ ។ ជាពិសេស រាល់កុមារដែលត្រូវបានដកហូតសេរីភាពត្រូវតែបំបែកចេញពីមនុស្សពេញវ័យ លើកលែងតែផលប្រយោជន៍ល្អបំផុតរបស់ កុមារតំរូវមិនឱ្យធ្វើយ៉ាងនេះ ហើយកុមារទាំងនេះត្រូវតែមានសិទ្ធិរក្សាការទាក់ទងជាមួយគ្រួសារខ្លួនតាមរយៈសំបុត្រឆ្លើយឆ្លងនិងការជួបសួរសុខទុក្ខ លើកលែងតែក្នុងកាលៈទេសៈជាពិសេសចេញ

(ឃ) រាល់កុមារដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិទទួលបានយ៉ាងឆាប់រហ័សនូវការជួយឧបត្ថម្ភផ្នែកផ្លូវច្បាប់ និង ក្នុងផ្នែកផ្សេងៗទៀតដែលសមស្របព្រមទាំងមានសិទ្ធិក្នុងការតវ៉ាពីនីត្យានុកូលភាព (ភាពស្របច្បាប់ Legality) នៃការដកហូតសេរីភាពខ្លួននេះ នៅចំពោះមុខតុលាការ ឬអាជ្ញាធរដែលមាន

សមត្ថកិច្ចដែលឯករាជ្យ និង ដែលមិនលំអៀង ហើយនិងមានសិទ្ធិទទួលបានសេចក្តីសំរេចយ៉ាងឆាប់រហ័យចំពោះទង្វើនេះ ។

**មាត្រា ៣៨**

១. រដ្ឋជាភាគីសន្យាគោរព និង ធានាឱ្យមានការគោរពនូវបទបញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលត្រូវអនុវត្តមកលើខ្លួននៅក្នុងជំលោះដោយអាវុធ ហើយដែលមានការទាក់ទិនដល់កុមារ ។

២. រដ្ឋជាភាគីប្រកាន់យកវិធានការទាំងអស់ដែលអាចធ្វើទៅបានដើម្បីធានាថា បុគ្គលដែលមិនទាន់ដល់អាយុ១៥ឆ្នាំ មិនត្រូវឱ្យចូលរួមដោយផ្ទាល់នៅក្នុងចំបាំងឡើយ ។

៣. រដ្ឋជាភាគីជៀសវាងមិនកេណ្ឌរើសបុគ្គល ដែលមានអាយុមិនទាន់ដល់១៥ឆ្នាំឱ្យចូលក្នុងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនឡើយ ។ នៅពេលកេណ្ឌរើសក្នុងចំណោមបុគ្គលទាំងឡាយដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ តែមិនទាន់ដល់អាយុ១៨ឆ្នាំនោះ រដ្ឋជាភាគីត្រូវជ្រើសរើសអ្នកដែលមានអាយុច្រើនជាងគេជាអាទិភាព ។

៤. ស្របទៅតាមកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវការពារប្រជាជនស៊ីវិលនៅក្នុងជំលោះដោយអាវុធដោយអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិនោះ រដ្ឋជាភាគីនឹងប្រកាន់យកនូវរាល់វិធានការណ៍ដែលអាចធ្វើបានដើម្បីធានាគាំពារ និងការថែទាំដល់កុមារដែលត្រូវប៉ះពាល់ដោយជំលោះអាវុធ ។

**មាត្រា ៣៩**

រដ្ឋជាភាគីប្រកាន់យករាល់វិធានការសមស្របទាំងអស់ ដើម្បីជំរុញការស្តារផ្នែករាងកាយ និងផ្នែកចិត្តសាស្ត្រព្រមទាំងការបញ្ចូលក្នុងសង្គមវិញនូវកុមារ ដែលបានរងគ្រោះនូវការមិនថែទាំការជិះជាន់ ឬការបំពាន ទារុណកម្មបែបណាមួយ ឬដោយទំរង់ផ្សេងៗនៃការប្រព្រឹត្ត ឬការផ្តន្ទាទោសដែលឃោរឃៅ អមនុស្សធម៌ និង ដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ឬ ដោយសារជំលោះដោយអាវុធ ។ ការស្តារឡើងវិញ និងការបញ្ចូលក្នុងសង្គមវិញនេះ ត្រូវប្រព្រឹត្តិទៅក្នុងលក្ខណៈមួយដែលមានអំណោយផលដល់សុខភាព, ដល់ស្មារតីស្វ័យគោរព ហើយនិងដល់ភាពថ្លៃថ្នូររបស់កុមារ ។

## មាត្រា ៤០

១. កុមារដែលត្រូវគេសង្ស័យថា ចោទប្រកាន់ថា ឬត្រូវបានគេទទួលស្គាល់ថាបានប្រព្រឹត្តិបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌ រដ្ឋជាភាគីទទួលស្គាល់នូវសិទ្ធិរបស់កុមារនេះ ចំពោះការឱ្យមានការប្រព្រឹត្តិមកលើខ្លួនក្នុងលក្ខណៈមួយ ដែលសមនឹងការជំរុញស្មារតីនៃភាពថ្លៃថ្នូរ និងតម្លៃរបស់កុមារ ដែលពង្រឹងស្មារតីកុមារ ក្នុងការគោរពសិទ្ធិមនុស្ស និងសេរីភាពរបស់អ្នកដទៃ ហើយជាការប្រព្រឹត្តិមួយដែលគិតគូរដល់អាយុរបស់កុមារ ព្រមទាំងការចាំបាច់ក្នុងការជួយសំរួលការបញ្ចូលកុមារទៅក្នុងសង្គមវិញ ហើយនិងជួយសំរួលដល់កុមារឱ្យប្រកាន់យកនូវតួនាទីស្ថាបនាមួយនៅក្នុងសង្គម ។

២. ក្នុងទិសដៅនេះ នឹងដោយយោងទៅតាមរាល់បញ្ញត្តិនៃឯកសារអន្តរជាតិដែលទាក់ទិនទៅនឹងបញ្ហានេះ រដ្ឋជាភាគីត្រូវធានាជាពិសេសថា :

(ក) គ្មានកុមារណាម្នាក់ត្រូវបានសង្ស័យ ចោទប្រកាន់ ឬ ត្រូវបានទទួលស្គាល់ថាបានប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌ អាស្រ័យដោយទង្វើ ឬ ការខកខានទាំងឡាយណាដែលមិនត្រូវបានហាមឃាត់ ដោយច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិនៅក្នុងពេលដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើយ ។

(ខ) កុមារគ្រប់រូបដែលត្រូវបានសង្ស័យ ឬចោទប្រកាន់ថាបានប្រព្រឹត្តិនឹងបទល្មើសបទព្រហ្មទណ្ឌយ៉ាងហោចណាស់ត្រូវទទួលបាននូវកិច្ចធានាដូចខាងក្រោមនេះ :

ខ/១. ទទួលចាត់ទុកជាឥតកំហុសរហូតដល់ពេលណាដែលពិរុទ្ធភាពរបស់កុមារត្រូវបានកំណត់ស្របតាមច្បាប់

ខ/២. ទទួលបានពត៌មានជាបន្ទាន់ និង ដោយផ្ទាល់ស្តីពីបទចោទប្រកាន់ដែលមានមកលើខ្លួន បើសិនជាពុំនោះសោតទទួលតាមរយៈឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ខ្លួន ហើយនិងទទួលបាននូវកិច្ចជំនួយឧបត្ថម្ភសមស្របជាផ្លូវច្បាប់ ឬក្នុងទំរង់ផ្សេងៗទៀតក្នុងការរៀបចំ និងដាក់ចេញនូវកិច្ចការពារខ្លួន

ខ/៣. ទទួលបានការដោះស្រាយសំណុំរឿងដោយគ្មានការយឺតយ៉ាវពីសំណាក់អាជ្ញាធរ ឬ ស្ថាប័នតុលាការដែលមានសមត្ថកិច្ច ដែលស្វ័យភាពដែលមិនលំអៀងនៅ

ក្នុងការជំនុំជំរះជំសមរម្យមួយដែលស្របច្បាប់ និងដោយមានជំនួយឧបត្ថម្ភផ្នែកច្បាប់ និង ផ្សេងៗទៀត និង ប្រសិនបើមិនផ្ទុយនឹងផលប្រយោជន៍ល្អបំផុតរបស់កុមារនោះ ជាពិសេសដោយយោងទៅលើអាយុ ឬ ស្ថានភាពរបស់កុមារដោយមានវត្តមានរបស់ឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារផង

ខ/៤. មិនត្រូវបានទទួលការបង្ខិតបង្ខំឱ្យធ្វើជាសាក្សី ឬទទួលសារភាពកំហុសណាឡើយ ទទួលសាកសួរ ឬចាត់ចែងឱ្យសាកសួរសាក្សីដើមចោទ និងអញ្ជើញឱ្យចូលរួមព្រមទាំងទទួលសាកសួរសាក្សីចុងចោទក្នុងល័ក្ខខ័ណ្ឌស្មើភាព

ខ/៥. បើសិនជាត្រូវបានគេទទួលស្គាល់ថាបានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ កុមារអាចតវ៉ាសុំសើរើ សេចក្តីសំរេចនេះ ឬ សុំសើរើរាល់វិធានការឯទៀត ដែលបានធ្វើឱ្យកើតជាសេចក្តីសំរេចបែបនេះនៅមុខអាជ្ញាធរថ្នាក់លើ ឬ ស្ថាប័នតុលាការដែលមានសមត្ថកិច្ច ស្វ័យភាព និងដែលមិនលំអៀងដោយយោងតាមលំនាំច្បាប់ ។

ខ/៦. ទទួលបានដោយឥតគិតថ្លៃនូវជំនួយរបស់អ្នកបកប្រែ បើសិនជាកុមារមិនអាចស្តាប់បាន ឬ មិនអាចនិយាយភាសាដែលត្រូវប្រើនោះបានទេ

ខ/៧. ជីវិតឯកជនរបស់កុមារត្រូវបានគោរពទាំងស្រុងនៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី

៣. រដ្ឋជាភាគីត្រូវខំស្វះស្វែងជំរុញនូវការចាត់តាំងច្បាប់ នីតិវិធី អាជ្ញាធរ និង ស្ថាប័នទាំងឡាយសំរាប់ទទួលបន្ទុកជាពិសេសលើបញ្ហាកុមារដែលត្រូវគេសង្ស័យ ចោទប្រកាន់ ឬ ត្រូវបានគេចាត់ទុកថាបាន ប្រព្រឹត្តិបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ហើយជាពិសេសគឺ :

(ក) ការកំណត់កំរិតអាយុតិចបំផុតមួយ ដែលក្រោមពីនេះកុមារត្រូវបានចាត់ទុកថាមិនមានសមត្ថភាពនឹងប្រព្រឹត្តិបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌបាន

(ខ) បើសិនជាមានការសមរម្យ និង បើមានសេចក្តីប្រាថ្នាផង ការប្រកាន់យកវិធានការណ៍ទាក់ទិននឹងកុមារប្រភេទនេះ ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីផ្នែកតុលាការ

ឱ្យតែធានាថាសិទ្ធិមនុស្ស ហើយនិងរាល់កិច្ចការធានាផ្នែកផ្លូវច្បាប់ត្រូវបាន គោរពទាំងស្រុង ។

៤. ក្រៅពីការរក្សានៅក្នុងមន្ទីរអប់រំ មានបញ្ញត្តិគ្រប់គ្រងជាច្រើនប្រការទៀត ដូចជាការថែទាំ ការតម្រែតម្រង់ និងការពិនិត្យគ្រប់គ្រង ការផ្តល់មតិទូន្មាន ការសាកល្បង ការដាក់ឱ្យរស់នៅតាមគ្រួសារ កម្មវិធីអប់រំទូទៅ និង អប់រំវិជ្ជាជីវៈ ព្រមទាំងដំណោះស្រាយផ្សេងទៀតដែលអាចប្រើប្រាស់បាន ដើម្បីធានាថាកុមារត្រូវបានទទួលការថែទាំមួយសមស្របជាមួយនឹងផាសុខភាពរបស់ខ្លួន ហើយដែលស៊ីគ៌រតគ្នានឹងស្ថាន ភាពរបស់កុមារផងនឹងទំរង់នៃបទល្មើសនោះផង ។

## មាត្រា ៤១

គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះធ្វើឱ្យប៉ះពាល់ដល់បញ្ញត្តិដទៃទៀត ដែលមានអំណោយផលល្អជាងក្នុងការធ្វើឱ្យមានការគោរពដល់សិទ្ធិទាំងឡាយរបស់កុមារឡើយ ហើយដែលមានចែងនៅក្នុង :

(ក) ច្បាប់របស់រដ្ឋជាភាគី ឬ

(ខ) ច្បាប់អន្តរជាតិដែលមានជាធរមានចំពោះរដ្ឋនោះ ។

## ភាគ ២

## មាត្រា ៤២

រដ្ឋជាភាគីសន្យាថា នឹងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដោយប្រើមធ្យោបាយសមស្រប និងដ៏សកម្មនូវគោលការណ៍ និង បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះទាំងដល់មនុស្សពេញវ័យ ទាំងដល់កុមារ ។

## មាត្រា ៤៣

១. ដើម្បីត្រួតពិនិត្យនូវភាពចំរីនលូតលាស់ទាំងឡាយនៃរដ្ឋជាភាគី ក្នុងកាតព្វកិច្ចនានារបស់ខ្លួន ដែលបានសន្យានៅក្នុងអនុសញ្ញានេះ ត្រូវបង្កើតគណៈកម្មាធិការមួយសំរាប់ទទួលបន្ទុកសិទ្ធិកុមារដែលនឹងមានភារកិច្ចដូចបានកំណត់ខាងក្រោយនេះ ។

២. គណៈកម្មាធិការមានសមាជិកអ្នកឯកទេសចំនួនដប់នាក់ដែលប្រកបដោយសីលធម៌ខ្ពស់ និងមានការទទួលស្គាល់ទៅលើផ្នែកសមត្ថកិច្ចក្នុងវិស័យដែលជាមុខសញ្ញានៃអនុសញ្ញានេះ ។ សមាជិកនៃគណៈកម្មាធិការនេះនឹងត្រូវបោះឆ្នោតជ្រើសតាំងឡើងដោយរដ្ឋជាភាគីក្នុងចំណោមពលរដ្ឋរបស់ខ្លួន ហើយនិងបំពេញការងារក្នុងឋានៈផ្ទាល់ខ្លួន និងដោយយោលទៅលើការបែងចែកសមស្របតាមភូមិសាស្ត្រ និងស្របទៅតាម ប្រព័ន្ធច្បាប់សំខាន់ៗផងដែរ ។

៣. សមាជិកទាំងឡាយនៃគណៈកម្មាធិការនឹងត្រូវជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតជាសំងាត់លើបញ្ជីរាយនាមមួយ ដែលស្នើឡើងដោយរដ្ឋជាភាគីទាំងឡាយ ។ រដ្ឋជាភាគីនីមួយៗអាចស្នើបេក្ខជនបានម្នាក់ក្នុងចំណោមពលរដ្ឋផ្ទាល់ខ្លួនរបស់ខ្លួន ។

៤. ការបោះឆ្នោតជាលើកដំបូងបង្អស់មិនត្រូវឱ្យយូរលើសពីប្រាំមួយខែក្រោយពីអនុសញ្ញានេះចូលជាធរមានឡើយ ហើយនៅពេលក្រោយៗមកទៀតជារៀងរាល់ឆ្នាំទីពីរ ។ បួនខែយ៉ាងតិចបំផុតមុនដល់ពេលកំណត់នៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិនឹងផ្ញើដល់រដ្ឋជាភាគីទាំងឡាយស្នើសុំឱ្យឧទ្ទេសនាមបេក្ខជនរបស់ខ្លួនក្នុងរយៈពេលពីរខែ ។ អគ្គលេខាធិការនឹងរៀបចំបញ្ជីឈ្មោះបេក្ខជនដែលត្រូវបានស្នើឡើងនោះតាមលំដាប់អក្សរ ហើយនិងបញ្ជូនបញ្ជីនេះទៅរដ្ឋជាភាគីទាំងឡាយនៃអនុសញ្ញានេះ ។

៥. ការបោះឆ្នោតនឹងត្រូវធ្វើឡើងក្នុងសម័យប្រជុំនៃរដ្ឋជាភាគីទាំងឡាយនៅទីស្នាក់ការអង្គការសហប្រជាជាតិ ហើយដែលត្រូវបានកោះឡើងដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ នៅក្នុងសម័យប្រជុំដែលទាមទារវត្តមានពីរភាគបីនៃរដ្ឋជាភាគីទើបយកជាការបាននោះ អ្នកដែលជាប់ជាសមាជិកនៃគណៈកម្មាធិការ គឺបេក្ខជនណាដែលទទួលសំឡេងច្រើនជាងគេបំផុត និង ដែលបានសំឡេងភាគច្រើនដាច់ខាតនៃអ្នកតំណាងរដ្ឋជាភាគីដែលមានវត្តមាននៅក្នុងសម័យប្រជុំ និង ដែលបានបោះឆ្នោត ។

៦. សមាជិកនៃគណៈកម្មាធិការ នឹងត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់បួនឆ្នាំ ។ សមាជិកទាំងនេះអាចឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាថ្មីទៀតបាន នៅពេលណាដែលមានការឧទ្ទេសនាមជាថ្មី ។ អាណត្តិរបស់សមាជិកប្រាំនាក់ដែលបានជាប់ឆ្នោតក្នុងពេលបោះឆ្នោតលើកទីមួយនោះ នឹង

ត្រូវចប់តែក្នុងរយៈពេល ពីរឆ្នាំប៉ុណ្ណោះ ។ ក្រោយពីការបោះឆ្នោតលើកទីមួយបានចប់សព្វគ្រប់ភ្លាម ឈ្មោះរបស់សមាជិកទាំងប្រាំនាក់ នេះត្រូវប្រធានអង្គប្រជុំជាអ្នកចាប់ឆ្នោត ។

៧. បើសិនជាមានសមាជិកនៃគណៈកម្មាធិការទទួលមរណភាព ឬសុំឈប់ ឬដោយសំអាងលើប្រការណាមួយថាខ្លួនមិនអាចបំពេញភារកិច្ចរបស់គណៈកម្មាធិការបានទេនោះ រដ្ឋជាភាគីដែលបានឧទ្ទេសនាមសមាជិកនេះ នឹងចាត់តាំងអ្នកឯកទេសម្នាក់ទៀតក្នុងចំណោមពលរដ្ឋខ្លួនឱ្យបំពេញអាណត្តិនៅសល់ក្នុងលក្ខខ័ណ្ឌដែលចំណាត់តាំងត្រូវទទួលបានការយល់ព្រមពីគណៈកម្មាធិការផង ។

៨. គណៈកម្មាធិការនឹងអនុម័តបញ្ញត្តិនីតិវិធីរបស់ខ្លួនផ្ទាល់ ។

៩. គណៈកម្មាធិការនឹងជ្រើសតាំងមន្ត្រីផ្លូវការរបស់ខ្លួនសំរាប់រយៈកាលពីរឆ្នាំ ។

១០. សម័យប្រជុំរបស់គណៈកម្មាធិការនឹងត្រូវធ្វើឡើងជាធម្មតានៅទីស្នាក់ការនៃអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របណាមួយទៀតអាស្រ័យដោយការកំណត់របស់ គណៈកម្មាធិការ ។ គណៈកម្មាធិការនឹងប្រជុំរៀងរាល់ឆ្នាំ ។ រយៈពេលនៃការប្រជុំរបស់គណៈកម្មាធិការនឹងត្រូវកំណត់ ឬបើចាំបាច់កែប្រែឡើងវិញដោយរដ្ឋជាភាគីនៃអនុសញ្ញានេះ ក្នុងលក្ខខ័ណ្ឌដែលការសំរេចនេះមានការយល់ព្រមពីមហាសន្និបាតនៃអង្គការសហប្រជាជាតិផង ។

១១. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិនឹងឧបត្ថម្ភបុគ្គលិក ព្រមទាំងឧបករណ៍ប្រើប្រាស់ចាំបាច់ផ្សេងៗសំរាប់ឱ្យគណៈកម្មាធិការអាចបំពេញភារកិច្ចខ្លួនបានដោយប្រសិទ្ធិភាព នៅក្នុងអនុសញ្ញានេះ ។

១២. ដោយមានការយល់ព្រមពីមហាសន្និបាត សមាជិកនៃគណៈកម្មាធិការដែលត្រូវបានចាត់ចែងឡើងតាមលំនាំអនុសញ្ញានេះ នឹងទទួលប្រាក់ខែពីថវិការបស់អង្គការសហប្រជាជាតិក្នុងកំរិត និងលក្ខខ័ណ្ឌដែលមហាសន្និបាតបានសំរេច ។

**មាត្រា ៤៤**

១. រដ្ឋជាភាគីសន្យាដាក់ជូនគណៈកម្មាធិការតាមរយៈអគ្គលេខាធិការអង្គការស ប្រជាជាតិ នូវរបាយការណ៍ស្តីពីវិធានការនានាដែលខ្លួនបានប្រកាន់យក ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពដល់សិទ្ធិ

ទាំងឡាយដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ ហើយនិងវឌ្ឍនភាពដែលមាននៅ
ប្រើប្រាស់សិទ្ធិទាំងនេះ :

(ក) ក្នុងរយៈពេលពីរឆ្នាំក្រោយពីអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋជ
ដែលទាក់ទិន

(ខ) បន្ទាប់មកទៀតរៀងរាល់ប្រាំឆ្នាំម្តង ។

២. របាយការណ៍ដែលបានធ្វើឡើងដោយអនុលោមតាមមាត្រានេះ ត្រូវលើកឡើង
និងការលំបាកនានា បើសិនជាមាន ដែលមានឥទ្ធិពលដល់ការធ្វើឱ្យបានសំរេចនូវកាតព្វកិច្ចទាំង
ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ របាយការណ៍ត្រូវផ្តល់ផងដែរនូវពត៌មានគ្រប់គ្រាន់ដើ
ឱ្យគណៈកម្មាធិការមានការយល់ដឹងចាំបាច់សព្វគ្រប់ស្តីពីការអនុវត្តន៍អនុសញ្ញានេះ នៅក្នុង
ដែលមានទាក់ទិន ។

៣. រដ្ឋជាភាគីដែលបានដាក់ជូនគណៈកម្មាធិការនូវរបាយការណ៍គ្រប់គ្រាន់សព្វគ្រប់
ដំបូង ហើយនៅក្នុងរបាយការណ៍ក្រោយៗមកទៀតដែលត្រូវដាក់ជូនគណៈកម្មាធិការ ដោយអនុ
តាមកថាខ័ណ្ឌ១ (ខ) នៃមាត្រានេះមិនចាំបាច់លើកឡើងវិញពីពត៌មានជាមូលដ្ឋានដែលបានលើ
ពីមុននោះឡើយ ។

៤. គណៈកម្មាធិការអាចមានសំណើដល់រដ្ឋជាភាគីនូវពត៌មានបន្ថែមទាក់ទិនទៅ
អនុវត្តន៍អនុសញ្ញានេះ ។

៥. តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម គណៈកម្មាធិការដាក់របាយការណ៍ស្តី
ភាពរបស់ខ្លួនជូនមហាសន្និបាតរៀងរាល់ពីរឆ្នាំម្តង ។

៦. រដ្ឋជាភាគីត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅក្នុងប្រទេសនូវរបាយការណ៍របស់

**មាត្រា ៤៥**

ដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការអនុវត្តន៍អនុសញ្ញានេះ និង ដើម្បីលើកទឹកចិ
កិច្ចសហប្រតិបត្តិការជាអន្តរជាតិ នៅក្នុងវិស័យដែលជាមុខសញ្ញានៃអនុសញ្ញានេះ :

(ក) ទីភ្នាក់ងារឯកទេសនៃអង្គការសហប្រជាជាតិ មូលនិធិរបស់អង្គការសហប្រជាជាតិសំរាប់កុមារ ហើយនិងរាល់ស្ថាប័ននានានៃអង្គការសហប្រជាជាតិ មានសិទ្ធិចាត់តាំងតំណាងខ្លួនឱ្យទៅចូលរួមក្នុងការត្រួតពិនិត្យការអនុវត្តន៍បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះដែលទាក់ទិននឹងមុខការរបស់ខ្លួន ។ គណៈកម្មាធិការអាចអញ្ជើញទីភ្នាក់ងារឯកទេស មូលនិធិរបស់អង្គការសហប្រជាជាតិសំរាប់កុមារ ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតដែលខ្លួនយល់ថាសមស្រប ដើម្បីផ្តល់មតិឯកទេសស្តីពីការអនុវត្តន៍នៅក្នុងវិស័យដែលទាក់ទិនទៅនឹងមុខការរបស់ខ្លួនផ្ទាល់ ។ គណៈកម្មាធិការអាចអញ្ជើញទីភ្នាក់ងារឯកទេស មូលនិធិរបស់អង្គការសហប្រជាជាតិរបស់កុមារ ឬស្ថាប័នផ្សេងទៀតរបស់អង្គការសហប្រជាជាតិឱ្យដាក់ជូនខ្លួននូវរបាយការណ៍ស្តីពីការអនុវត្តន៍អនុសញ្ញានេះនៅក្នុងវិស័យទាំងឡាយដែលទាក់ទិនទៅនឹងដែនសកម្មភាពរបស់ ស្ថាប័នទាំងនេះ

(ខ) នៅពេលដែលយល់ថាចាំបាច់ គណៈកម្មាធិការនឹងដាក់ជូនទីភ្នាក់ងារឯកទេស មូលនិធិ អង្គការសហប្រជាជាតិសំរាប់កុមារ និង ស្ថាប័នមានសមត្ថកិច្ចឯទៀតនូវរបាយការណ៍របស់រដ្ឋជាភាគីណាដែលមានសំណើ ឬ បង្ហាញថាខ្លួនត្រូវការមតិណែនាំ ឬ ជំនួយឧបត្ថម្ភផ្នែកតិចនិចនានា ហើយបើសិនជាមានដោយមានភ្ជាប់ជាមួយនូវមតិសំគាល់ និងសំណើនានារបស់គណៈកម្មាធិការ នៅលើសំណើ ឬការចង្អុលបង្ហាញទាំងនេះ

(គ) គណៈកម្មាធិការអាចធ្វើការផ្តាំផ្ញើដល់មហាសន្និបាតសុំឱ្យមានសំណើដល់អគ្គលេខាធិការឱ្យចាត់ចែងក្នុងនាមគណៈកម្មាធិការឱ្យមានជាការសិក្សាស្រាវជ្រាវលើបញ្ហាដោយឡែកដែលទាក់ទិនដល់កុមារ

(ឃ) គណៈកម្មាធិការអាចធ្វើសំណើ និងការផ្តាំផ្ញើជាទូទៅដោយឈរលើមូលដ្ឋាននៃពត៌មាន ដែលបានទទួលដោយអនុលោមតាមមាត្រា៤៤ និង ៤៥នៃអនុសញ្ញានេះ ។ សំណើ និងការផ្តាំផ្ញើជាទូទៅនេះ នឹងត្រូវបញ្ជូនទៅរាល់រដ្ឋជាភាគីដែល

មានទាក់ទិន ហើយនិងជូនដល់មហាសន្និបាត ហើយបើសិនជាមាន ដោយភ្ជាប់ជាមួយនូវមតិយោបល់របស់រដ្ឋជាភាគីផង ។

## ភាគ ៣

### មាត្រា ៤៦

អនុសញ្ញាត្រូវបានបើកចំហសំរាប់ចុះហត្ថលេខាដល់គ្រប់រដ្ឋទាំងអស់ ។

### មាត្រា ៤៧

អនុសញ្ញានេះត្រូវទទួលការឱ្យសច្ចាប័ន ។ ឯកសារនៃការការឱ្យសច្ចាប័ននេះ ត្រូវដំកល់ទុកនៅនឹងអគ្គលេខាធិការសហប្រជាជាតិ ។

### មាត្រា ៤៨

អនុសញ្ញានេះបើកឱ្យមានការចូលរួមពីគ្រប់រដ្ឋទាំងអស់ ។ ឯកសារស្តីពីការចូលរួមនឹងត្រូវដំកល់ទុកនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

### មាត្រា ៤៩

១. អនុសញ្ញានេះនឹងចូលជាធរមានសាមសិបថ្ងៃក្រោយពីឯកសារឱ្យសច្ចាប័ន ឬសុំចូលរួមទីម្ភៃត្រូវបានដំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិនោះមក ។

២. ចំពោះរដ្ឋនីមួយៗដែលបានឱ្យសច្ចាប័ន ឬដែលបានចូលរួមក្នុងអនុសញ្ញានេះ ក្រោយពីឯកសារនៃការឱ្យសច្ចាប័ន ឬការចូលរួមទីម្ភៃត្រូវបានដំកល់ទុកហើយនោះ អនុសញ្ញានេះនឹងចូលជាធរមាននៅសាមសិប ថ្ងៃក្រោយពីថ្ងៃដែលឯកសារឱ្យសច្ចាប័ន ឬការចូលរួមរបស់រដ្ឋនោះត្រូវបានដំកល់ទុកហើយ ។

### មាត្រា ៥០

១. គ្រប់រដ្ឋជាភាគីទាំងអស់អាចស្នើវិសោធនកម្ម ហើយនិងដាក់សំណើនេះនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការ នឹងបញ្ជូនសំណើវិសោធនកម្មនេះទៅរដ្ឋជា

ភាគីទាំងឡាយ ដោយស្នើសុំឱ្យរដ្ឋជាភាគីទាំងនោះផ្តល់ដំណឹងមកដល់ខ្លួនថាតើគាំទ្រការប្រជុំសន្និសិទនៃរដ្ឋជាភាគីដើម្បីពិនិត្យនិងបោះឆ្នោតលើសំណើនោះឬទេ ។ បើសិនជានៅក្នុងរយៈពេលបួនខែក្រោយពីការជូនដំណឹងនេះ មានមួយភាគបីយ៉ាងតិចនៃរដ្ឋជាភាគីទាំងឡាយបានគាំទ្រសន្និសិទប្រភេទនេះ អគ្គលេខាធិការនឹងកោះប្រជុំក្រោមការចាត់ចែងរបស់អង្គការសហប្រជាជាតិ ។ រាល់វិសោធនកម្មដែលត្រូវបានអនុម័តដោយសំឡេងភាគច្រើននៃរដ្ឋជាភាគីដែលមានវត្តមាននិងដែលបានបោះឆ្នោតនៅក្នុងសន្និសិទនោះ ត្រូវដាក់ជូនមតិឯកភាពពីមហាសន្និបាត ។

២. រាល់វិសោធនកម្ម ដែលត្រូវបានអនុម័តដូចមានចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះនឹងចូលជាធរមាននៅពេលដែលបានការឯកភាពពីមហាសន្និបាតនៃអង្គការសហប្រជាជាតិ និង ទទួលយកដោយសំឡេង ភាគច្រើនពីរភាគបីនៃរដ្ឋជាភាគី ។

៣. នៅពេលណាដែលវិសោធនកម្មចូលជាធរមាន វិសោធនកម្មនេះមានអនុភាពជាកំហិតទៅលើរដ្ឋជាភាគីទាំងឡាយដែលបានទទួលយក ។ រដ្ឋជាភាគីផ្សេងទៀតស្ថិតនៅត្រឹមតែក្រោមអនុភាពនៃបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ហើយនិងរាល់វិសោធនកម្មមុនៗមក ដែលខ្លួនបានទទួលយកតែប៉ុណ្ណោះ ។

**មាត្រា ៥១**

១. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ទទួលនិងបញ្ជូនដល់គ្រប់រដ្ឋទាំងអស់នូវអត្ថបទនៃការដាក់ល័ក្ខខ័ណ្ឌរបស់រដ្ឋនានាដែលបានធ្វើឡើងនៅពេលឱ្យសច្ចាប័ន ឬ នៅពេលសុំចូលរួមនោះ ។

២. ការដាក់លក្ខខ័ណ្ឌណាមួយដែលផ្ទុយនឹងកម្មវត្ថុ ហើយនិងគោលដៅនៃអនុសញ្ញានេះមិនត្រូវបានអនុញ្ញាតិឡើយ ។

៣. ការដាក់លក្ខខ័ណ្ឌនេះអាចដកវិញបានគ្រប់ពេលវេលាដោយការជូនដំណឹងជាលាយល័ក្ខអក្សរស្តីពីបញ្ហានេះដល់អគ្គលេខាធិការអង្គការសហប្រជាជាតិដែលបន្ទាប់មកនឹងជូនដំណឹងដល់រដ្ឋឯទៀតៗ ។ ការជូនដំណឹងជាលាយល័ក្ខអក្សរនឹងមានប្រសិទ្ធិភាពនៅថ្ងៃដែលអគ្គលេខាធិការបានទទួល ។

**មាត្រា ៥២**

រដ្ឋជាភាគីអាចសុំរំសាយពីអនុសញ្ញានេះបានដោយការជូនដំណឹងជាលាយល័ក្ខអក្សរដល់អគ្គលេខាធិការសហប្រជាជាតិ ។ ការសុំរំសាយខ្លួនមានប្រសិទ្ធិភាពមួយឆ្នាំក្រោយពីពេលដែលអគ្គលេខាធិការ បានទទួលការជូនដំណឹងនេះ ។

**មាត្រា ៥៣**

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានតាំងជាអ្នកទទួលរក្សាទុកអនុសញ្ញានេះ ។

**មាត្រា ៥៤**

សំណៅដើមនៃអនុសញ្ញាដែលមានអត្ថបទជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្បាញ មានតម្លៃស្មើគ្នា ហើយនិងត្រូវដំកល់ទុកនៅនឹងអគ្គលេខាធិការសហប្រជាជាតិ ។

ជាបន្ទាល់នៃកិច្ចនេះ ភាគីអ្នកចុះហត្ថលេខាខាងក្រោម ដែលបានទទួលការអនុញ្ញាតិយ៉ាងពេញលេញពីរដ្ឋាភិបាលរបស់ខ្លួនបានចុះហត្ថលេខានៅលើអនុសញ្ញានេះ ។